# ស្តេចចៃ

បទផាត់ជាយ

យកលំនាំតាមបទ

អញ្ជើញអនចេញមកផ្ទឹម

អឹងអឺយ! ព្រលឹម ព្រលឹមសង្ឃឹមព្រឹកអឺយ! ល្ងាចសែនរលឹក ទឹកខ្វាចតែចៃ!
ចៃខាំចាំខោក! ចូកកម្ចាត់ចៃអឺយ! ចៃចោលចោលប៉ៃអ្អើយ! ដៃត្រូវក្បាលអើយ!
បែកឈាមក្រហមច្រាល ហៃអឹងអឺយ បណ្តាលថ្នាលទឹកភ្នែកអើយ!
អឹងអឺយ! អ្នកវាយ! នាយវិលវិកិលអើយឱ! គិតគួរ ឱ! គួរអាសូរដល់ក្បាល វាលរងកម្មអើយ!
ឈាមស្រហូរស្រក់ តក់! តក់! ដក់ថ្លាសត្រងាលអើយ ឱ! ក្រហមឆ្អិនឆ្អៅ ខ្លួនខ្មៅចិត្តខ្មៅ
ស្តេចចៃកម្មៅ! ហៃអឹងអឺយ! ឈប់ទៅខៃក្បាលខ្មែរអឺយ!

## កំណត់កវី

*កំណាព្យសាបគំនិត សិតគំនុំ សមកំណើតកើតមកជាខ្មែរ តើនឹងត្រូវថៃទាំគាំទ្រជាតិរបៀបណា?*

*ក្រៅនៃតែកើតមកជាខ្មែរ ភ្វាមខ្មែរ ក៏មានឈាមជ័រជាខ្ញុំរបស់ម្ចាស់ជីវិតលើត្បូងដែលចំកោងខ្នងធ្វើជាស្តេច រួចជាស្រេចទៅហើយ!*

*ចៃជាសត្វចង្រៃ ជាប្រទាលផ្ញើប្រាណ ជាសត្វរំខានក្បាល! ... លុះត្រាតែក្បាលទៅជាត្រងោលត្រងាល ទើបចៃប្រាលប្រែ រហូតដល់ផ្ទាតដៃផ្ទាតជើង!...*

ពពួកចៃជ្រៃ ឈ្លើង ប្រែះ សត្វទាំងអស់នេះជាសត្វជញ្ជក់ឈាមជ័រ។

តើខ្មែរត្រូវតែកម្ចាត់ចៃដោយវិធីណាទើបគ្មានការខូចប្រយោជន៍ដល់ខ្លួន?

*ក្នុងការបើកបទតាមកំណត់*អញ្ជើញអនមកផ្ទឹម*គប្បីបងប្អូនខ្មែរញញឹមរាប់អានរលាក់សម្លេងបំផ្លែងន័យមួយ ឬពីរម៉ាត់បន្ថែមឬបន្ថយតាមការដែលអាចធ្វើទៅកើតដោយគ្រាន់តែប្រើពាក្យ*អឺយឬឱ*មកជំនួសដើម្បីចៀសវាង នូវការជ្រុលជ្រួសជ្រលួសន័យ ។*

*សូមអស់លោកប្រុសលោកស្រីមេត្តាខន្តិអភ័យទោសនូវការលើសលស់ខុសឆ្គងរំលងសេចក្តីផងទាំងពួង ។*

កវីវង្គតបុរី

ទ. គ. ស

# ឱ!សម្លេងវៃយំ

(ទំនុកទំនួញទុំទាវ)

១)ឱ!មេឃមីរ អ្ហើយស្រទុំ ផ្សែងហុយជិតជុំ ឃុំឈូកចម្បែង (ស្ងួន)
ភ្លើងឆេះព្រឹក្សព្រៃ ដីបែកក្រហែងអ្ហើយ ក្តិយកស្រែឯង
ក្រែងលោពុំសម អឺអឺអឹងអឺយ ៗ

២)ឱ!សម្លេងទោចថ្ងូរ គួរឲ្យអាសូរ សាសនាគោតម (ស្ងួន)
ព្រះសង្ឃសោយសោក លោកនៅសម្ងំអ្ហើយ អ្នកណាវាយដំ
បង្ខំគ្រប់គ្រង អឺអឺអឹងអឺយ ៗ

៣)ឱ!សម្លេងវៃយំ អកលាទ្រនំ ឃុំបាកបង្គង (ស្ងួន)
បន្តោលព្រំដែន ធ្វងដែនរំលងអ្ហើយ ខ្វាចក្រែងជំបង
សំពងបែកឈាម អឺអឺអឹងអឺយ ៗ

៤)ឱ!ស្រណោះផ្កាព្រៃ បានប្តីសេដ្ឋី ស្រីភ្ញូចវៃភ្វាម (ស្ងួន)
ជំទាវឡើងបុណ្យ យុនលែងរហាមអ្ហើយ រងផ្សែងសង្គ្រាម
តាមចិត្តប្រាថ្នា អឺអឺអឹងអឺយ ៗ

១)ឱ!សម្លេងវៃយំ ជួងចិត្តអើយឆេះងំ ដោយមន្តស្នេហា (ស្ងួន)
វៃមិនយល់ចិត្ត បោទស្រីសាវ៉ាអ្ហើយ វៃអើយមេត្តា
ផល់ផ្កាស្មោះពិត អឺអឺអឹងអឺយ ៗ

២)ឱ!ស្នេហ៍មានតែមួយ ជាបេះអ្ហើយជូងត្រួយ ពន្ធកជីវិត (ស្ងួន)
សង្គមបុណ្យស័ក្តិ បំបាក់សព្វសិទ្ធិអ្ហើយ បងអើយអាណិត
ចិត្តផ្កាភក្តិ អឺអឺអឹងអឺយ ៗ

៣)ក្នុងជាតិនេះប្រាថ្នា ឃុំជាសង្សារ ម្ចាស់ចិត្តផ្កាស្រី (ស្ងួន)
សូមជាតិខេមរា មេត្តាប្រណីអ្ហើយ ផល់ស្នេហ៍ប្រុសស្រី
ឃុំផ្កាផងចុះ អឺអឺអឹងអឺយ ៗ

# ប្រាក់ដួងនិងប្រាក់ដុល្លារ

យកលំនាំតាមសំបួរមាសទំនុករបស់លោក

## ស៊ីនស៊ីសាមុត

*១)សម័យប្រាក់ដួងហ្លួងស្ដាយប្ញស្សី    ដុល្លារសម័យភ័យបាត់ព្រៃឈើ*
*ព្រះគោព្រះកែវស្រស់*ស្រងើ[១]    *សត្វស្វាបហិចហើរស្ទើរឃាត់មិនឈ្នះ ។*
*២)ម្រឹគីម្រឹគាខ្លាតោដំរី    ទន្សោងគោព្រៃក្របីរមាស*
*រមាំងឈ្លូសទ្រោយទន្សាយស្ទុះស្ទុះ    រំពឹងបន់ព្រះព្រះធ្វើព្រងើយ ។*
*៣)សត្វផងផ្សងភ័ព្វសែនអាប់រស្មី    អាលោះអាល័យសេចក្ដីតោះតើយ*
*ពីរឿងដែលព្រះទ្រង់គង់នៅដើយ    ម៉្វះសមសត្វអើយបាត់បង់ព្រឹក្សព្រៃ!*
*៤)ខ្មែរផងរងទុក្ខទឹកមុខស្ញូកស្ញាំង    ដោយសារចម្បាំងខ្នាំងប្ញូនបុរី*
*សម្លាប់រង្គាលទីវាលភិតភ័យ*    ស្រងោចសិរី[២] ទឹកដីកំសត់[៣]!

ស្រងើ[១]=*ដែលងើបមុខបន្តិចចេញអាការឲ្យឃើញថាមានបើធ្វល់មិនជាក់លាក់ឬដែលមានមុខងើបបន្តិចយ៉ាងដើយសមរម្យ* **(តាមធម្មតាពីកំណើត)** ។

ស្រងោចសិរី[២]=*ទឹកលន្ទោបចិត្តអាណិតសិរី*(អានថាសេរី)*ដែលជាលម្អដែលគួរឲ្យស្រឡាញ់; សួស្ដី ស្រីសួស្ដី មង្គល ; ជោគ; សេចក្ដីសុខ សេចក្ដីចម្រើន; បុណ្យ បុណ្យភ័ព្វ ភ័ព្វព្រេង សំណាងល្អ; ព្រេង សំណាងល្អ; ទ្រព្យ; ការមានបាន លាភ; ឥស្សរភាព តេជះ អំណាច ; រាជស័ក្ដិ; ទិព្វស័ក្ដិ; ភគវតី; លក្ស្មី ។ល។*

ទឹកដីកំសត់[៣]=*ព្រោះឥតមានអ្នកដឹកនាំប្រសើររៀបដំណើរទៅកាន់សេចក្ដីសុខ សេចក្ដីត្រូវ សេចក្ដីល្អ ។*

## សំបួរមាស

១) សំបួរមាសអើយផ្លែលាក់សន្ទឹក    បងបួសហើយសឹកមកដណ្ដឹងស្រី
អក្ខរាបងលាក់ដាក់ក្រោមក្ដារគី    កែវកុំយកប្ដីមុនរដូវភ្ជុំ។
២) អកកាច់សំបុកកុកលាស់រោមថ្មី    ទំពាំងទូលដីប្ញស្សីបែកគុម្ព
ដាច់ខែអស្សុជកែវពេញក្រមុំ    ផ្ការីកជួបឃ្មុំឃុំសុំលំអង។
៣) ផ្កាដុះតាមផ្លូវរៀមមិនត្រូវការ    ចិត្តគួចប្រាថ្នាផ្កាក្នុងរបង
ផ្កាសំបួរមាសមានម្ចាស់គ្រប់គ្រង    ក្រពុំលើទងចាំបងថ្នមបី។
៤) ផ្កាដុះដីក្រុងមានជង់អន្ទាក់    ផ្កាអួនមានធ្នាក់ទាក់ភ្នែកកវី
ពេលបងឃើញផ្កាដូចបានឃើញស្រី    សូមកែវប្រណីសម្ដីបងផង។

# **ក្រីក្រ**

* យកលំនាំតាមសំនៀងឆ្នាំមុន*

១- ក្រីក្រក្រៀមក្រំក្រាស់ក្រែលគ្រួញក្រាបក្រង    ល្ហងលោមល្អិតល្អង
ឆ្លងឆ្លើយឆ្លៀវឆ្លាតឆ្លូកឆ្លៅ    សព្វសុខសោកាសោភាសោភ័ណសោកសៅ
កន្លង់កម្លៅ    នៅនានេបនិត្យន្ទួននាង។

២- ក្រីក្រតោកយ៉ាកលំបាកលំបិន    សៀមលាវយួនចិន
បង្ហិនបង្ហោចខ្មែរអស់    ខ្យត់ខ្សោយខ្សេវខ្សោះខ្សឹកខ្សួលខ្សឹបខ្សៀវរំដោះ
ទឹកដីស្រណោះ    ព្រោះជ្រោះជ្រលងដងព្រៃ!

បន្ទរ- យប់អឺយយប់យន់ខ្មែរបន់**សិរីអារ្យមេត្រី**    រៀងរាល់យប់ថ្ងៃ
ខ្មែរសែនអាល័យ**កម្ពុជា**    យប់អឺយយប់ស្ងាត់បាត់ខេមរា
ឱ្យខ្មែររំពឹងនរណា    បើ**កម្ពុជា**អន្តរាយ។

៣- ខ្មែរអឺយខ្ញុំមិនបំភ្លេចអ្នកទេ    អ្នកគាំទ្រថៃ
ជាតិខ្មែររឹតតែថ្លាថ្លៃ    រំពឹងបានសុខរាល់ពេលនិងរាល់យប់ថ្ងៃ
ខ្ញុំនឹកស្រមៃ    ដល់**ស្រី**ពុំមានក្តីភ្លេច៕

## **ឆ្នាំមុន**

### **អ៊ឹមសុងសឺម**

១- ឆ្នាំមុនបងបានជួបនឹងអូនម្តង    ច្រើនខែកន្លង
បងខានបានជួបស្រីពៅ    ទឹកភ្នែកសោកាលង់លុះឯណាឥឡូវ
បងចាំមើលផ្លូវ    បាត់សូន្យភ្លេចពាក្យសន្យា។

២- ឆ្នាំមុនបងបានជួបនឹងអូនស្រី    ពាក្យពេចន៍សម្តី
មានន័យដ៏ផ្អែមពិរោះ    តែក្នុងពេលនេះហេតុអ្វីក៏ប្រែក្រឡាស់
ភ្លេចស្នេហ៍យើងចាស់    បាត់កាយភ្លេចទាំងសម្តី។

បន្ទរ- យប់អឺយយប់យន់បងគន់មើលតែផ្លូវស្រី    អស់ប្រាំពីររាត្រី
បងសែនអាល័យស្នេហា    យប់អឺយយប់ស្ងាត់បាត់សង្សារ
ឱ្យខ្ញុំរំពឹងនរណា    បើចន្ទ្រាឃ្លាតឆ្ងាយ។

៣- អូនអឺយបងមិនអាចភ្លេចបានទេ    ស្រស់កែវមាសមេ
បងសែនស្នេហាពេកក្រៃ    រំពឹងថាជួបរាល់ពេលនិងរាល់រាត្រី
បងនឹកអាល័យ    ដល់ស្រីពុំមានពេលភ្លេច៕

## សម្លេងឆ្នោត

(យកលំនាំតាមសំនៀង)

## ក្រោមមេឃលើដី

របស់លោក

**ស៊ីនស៊ីសាមុត**

១- រាល់ស្រោយចំណោទ មានតែ ឆ្នោត មួយ សម្លេងលើកស្ទួយជំនួយប្រទេស
បងប្អូនរួមជាតិមិនឃ្លាតប្រហែស កសាងតំរិះឲ្យល្បីរន្ទឺ ៗ
២- ជីវិត រស់ បាន អាស្រ័យ មានធាតុ សព្វសត្វ រុក្ខជាតិ មិនឃ្លាត ពន្លឺ
រូប ខ្មែររស់រាន អាស្រ័យ ទង្វើ ទុកជាអំពើធ្វើផលជូនជាតិ ៗ
បន្ទរ- កើតក្នុងមួយជាតិ ជីវិត គ្មានអ្វីបើគិតជាងគ្រឿងផ្សំធាតុ
មានតែអង្គប្រាំប្រចាំអង្គធាតុ ដែលជនរួមជាតិ សង្ឃាត លុះក្ស័យ ៗ
៣- ទោះជាលោកិយក្លាយជា ធូលី ខ្មែរត្រូវសំភី មិន ឈ្លី ឈ្លើបដី
បោះឆ្នោត ជូនខ្មែរ ថែទាំ ទឹកដី សាសនាប្រណី ខ្មែរថែ កុសល ៕

## ក្រោមមេឃលើដី

១- ក្រោមមេឃលើដី មានតែ ស្រី មួយ ដែលជាជំនួយនៃរឿងជីវិត
រូបអូនស្នេហ៍អូនជាទឹកអម្រឹត ស្រោចស្រង់ជីវិតឱ្យមានដង្ហើម។
២- មច្ឆា រស់ បានអាស្រ័យគង្គា រុក្ខជាតិ នានា អាស្រ័យ សន្សើម
រូប បងរស់បាន អាស្រ័យ ថ្ងៃថ្មើម ទុកជាដង្ហើមផ្សើមរឿងសង្ខារ។
បន្ទរ- ក្នុងលោកនេះណា កល្យាណ គ្មានអ្វីសំខាន់ដល់បងឡើយណា
មានតែអូនមួយជាត្រួយជីវ៉ា ដែលរៀមសច្ចាប្រាថ្នា លុះក្ស័យ។
៣- ទោះជាផែនដីរលាយសោះសូន្យ ស្នេហ៍បងនិង អូន មិន សូន្យ ទេថ្ងៃ
ស្នេហ៍រស់ គង់វង់ រុងរឿងរាល់ថ្ងៃ គ្មានអ្វីប្រល័យស្នេហ៍យើង បានឡើយ៕

## ដីមួយសែនហិកតារ

៚តាមសំនៀងកណ្ដាលដួងចិត្ត៚

១- ទឹកដីខ្មែរមួយសែនហិកតារ ឱ្យយួនទន្ទ្រានកាប់ឆ្ការ
ជារឿងទុក្ខរីងរៃ លាហើយក្រហមក្រញូមចង្រៃ។
ក្នុងន័យស្នារលាចាកពៀរ ចៀសវាងវេរាជាអកុសល។

២- ជីវិតខ្មែរថៃទាំ**កម្ពុជា** ស្ដាយកេរដូនតា
ឥតបានការពារជិតដល់ ខ្មែរយើងទាំងឡាយរីករាយកម្មផល។
ត្រៀបត្រារក្សាកុសល ផុតអំពល់អម្រែកកម្ម។

បន្ទរ- សូមប្រកាសដល់ព្រះឈ្នះមារ ជួយដឹកនាំខេមរា
ថែកេរដូនតាមនោរម្យ សូមឱ្យចិន្ដានៃព្រះអង្គឥន្ទព្រហ្ម
យាងមកសណ្ឋិតប្រក់ព្រំ ព្រមតាមពង្រាងសន្យា។

៣- ឱ! ដល់វាលថ្នាលជីវិតសុខសាន្ត មានព្រះប្រធាន
លោកកុំមានចិត្តឫស្យា មានចិត្តអាណិតជីវិត ខេមរា។
ជួយខ្មែរផងណាក្សត្រា រៀរចាកកម្មពៀរលុះគ្រាអវសាន្ត៕

## កណ្ដាលដួងចិត្ត

ស៊ីនស៊ីសាមុត

១- ខ្ញុំរួចទោសផុតជ្រោះស្នេហា ស្ថានវិមានសោកា
ជារឿងទុក្ខរីងរៃ សូមលាហើយព្រោះ អស់និស្ស័យ។
ដើម្បីកុំឱ្យតណ្ហា ជេរដៀលខ្ញុំថាជាជនសំណល់។

២- ជីវិតថ្ងៃថៃជន្មវាសនា ស្ដាយលោហិតមាតា
ដែលអស់សង្ខារខានយល់ យើងទាំងពីរឆ្លងផុតស្ថានអំពល់។
រួមវាសនាសាងឫសគល់ ផុតផលពីអម្រែកកម្ម។

បន្ទរ- សូមប្រកាសដល់អស់ទេវតា ជួយនាំរឿងស្នេហា
កណ្ដាលដួងចិត្តនៃខ្ញុំ សូមឱ្យចិន្ដានៃបុប្ផាក្រពុំ
មករួបរួមមនោរម្យ ព្រមជាគូវាសនា។

៣- ឱ! កណ្ដាលថ្នាលជីវិតចុងក្រោយ អូនកុំបណ្ដោយ
ឱ្យចិត្តមានប្រេះឆា ជួយអាណិតដល់ជីវិត កំព្រា។
ជួយបងផងណាពុំងា រួមរស់ជាគ្នាលុះគ្រាអវសាន្ត៕

# វារីអគ្គិសនីទន្លេសេសាន

យកតាមលំនាំសំនៀង

## រាត្រីសេកុង

១- *ទន្លេសេសានរុញប្រានគង្គា* *ហូរជ្រែក ពសុធា ធារទឹកដីខ្មែរ*
*មិនគួរពួកយួនពួននៅ បំបែរ* *ថាមពល ជាតិខ្មែរ វារី ជាតិយើង ។*
២- *កម្លាំងភ្លើងបំភ្លឺ ពីវារី* *គួរខ្មែរសំភី ជួយជាវភ្លើងយើង*
*មិនត្រូវស្មោស្មន់បែរបន់ក្រុមឈ្លើង* *យួនលក់ឲ្យយើងភ្លើងខ្មែរយើងទេ ។*

បន្ទរ- *បច្ចេកទេសថ្មីល្បីល្បាញពិតហើយ* *ខ្មែរអើយ ចូរចាំ បណ្តាំគ្នាន់គ្នេរ*
*ខ្មែរណាពូកែរក្សាការកេរ* *ទឹកដី ផងខ្មែរ ត្រូវថែ ឲ្យបាន ។*

៣- *ទន្លេសេសានរស់រានមច្ឆា* *សត្វធាតុផងណា គង្គា ប្រស់ប្រោណ*
*ស្រោចស្រព្វជីវិត ឥតគិតរំខាន* *ស្រឡាញ់ រាប់អាន ជាតិណាដូចណា ៕*

## រាត្រីសេកុង

*សំនៀងអ្នកនាងហួយមាស*

១- រាត្រីសេកុងបានប្រុងប្រៀបប្រាណ ចាំប្រុសកល្យាណ ជាគូវាសនា
នៅក្រោមរស្មីច័ន្ទ្ររះភ្លឺថ្លា ក្រោមឆ្នេរ ជលសារ ដែលហូរហែង។
២- រាត្រីសេកុងត្រួយអនង្គចិត្ត អ្នកហាក់នឹងស្និទ្ធ ស្នេហ៍កែចម្បែង
ខ្ញុំនៅរង់ចាំតែម្នាក់ឯង ឱរាចម្បែងអូនរែងទន្ទឹង។

បន្ទរ- ជំនោរត្រជាក់ធ្លាក់មកដល់ហើយ ផ្កាអើយ យាងទៅណាចាត់ដំណឹង
ព្រះច័ន្ទ្រក៏យាងស្ងាត់បាត់សូន្យឈឹង ឱ្យខ្ញុំរំពឹងរំពឹង ម្ដេចបាន។

៣- រាត្រីសេកុងហូរឆ្ងាយម្ល៉េះណា ជលនេត្រសោកាខ្លោចផ្សា ក្នុងប្រាណ
ជាតិនេះប្រហែល ជាខ្ញុំមិនបាន រូបប្រុស កល្យាណ ជាគូគាប់ឡើយ៕

## ដងស្ទឹងសង្កែ

យកតាមលំនាំចំរៀង

## ទឹកស្ទឹងស្លាគូ

១- ដងស្ទឹងសង្កែ ប្រែប្រួលបរន្ត   ហាក់ដូចអាក់អន់
ស្រពន់ស្រពាប់ ចិន្តា   ប្រែប្រួលបបួល គន្ធា
ស្រោចស្រព ជីវ៉ា   ជីវិត ជាតិខ្មែរ ។
២- ធម្មជាតិ មាត់ស្ទឹង ទន្ទឹងខ្មែរផង   មកជួយគ្រប់គ្រង
អន្លង ជីវិត មិនផិតដងស្ទឹង   រំពឹងបំពេ
ផ្ទេរអារម្មណ៍ខ្មែរ   ស្និទ្ធស្នេហ៍ ថែចិត្ត ។
បន្ទរ- ខ្មែរអើយ នេះហើយដងស្ទឹងសង្កែ   ហូរកាត់ វាលស្រុកសង្កែ វាលស្រែ
សំកុកបាត់មុខ យល់ទុក្ខឥតល្ហែ   អាប់អោនរស្មីឲ្យខ្មែរខ្វោចចិត្ត ។
៣- ឱ! ស្ទឹងកំសត់បត់បែនតាមស្រុក   គន្ធាលាក់មុខ
ទុក្ខខ្មៅ ងងឹត ស្ទឹងសំកុក   ទុក្ខខ្វោចផ្សា ជីវិត
អនាថអាណិត   ដល់ចិត្ត ខ្មែរផង ៗ

## ទឹកស្ទឹងស្លាគូ

*សំនៀងអ្នកនាងរស់ សិរីសុទ្ធា*

១- ទឹកស្ទឹងស្លាគូ ហូរចាកច្រាំងទៅ   ចោលរូបស្រីនៅ
តែឯងឯកា ទឹកភ្នែក   ហូរលាយនឹងព្រះគង្គា
ផ្ញើទៅ សង្សារ   ដែលឃ្លាត ទៅឆ្ងាយ។
២- ធម្មជាតិ មាត់ស្ទឹង ទន្ទឹងប្រុសបង   ដែលជាគូគ្រង
ផ្ញើចិត្ត ផ្ញើកាយ ធ្លាប់ងូតទឹកស្ទឹង   រត់លេង សប្បាយ
អូនសែនស្តាយកាយ   ក្លិនខ្លួន សង្សារ។
បន្ទរ- បងអើយនេះហើយដងស្ទឹងកំសត់   រាល់ថ្ងៃ យើងបានសន្ទូត ជួបគ្នា
ពេលនេះមិនឃើញ យល់តែគង្គា   ចាំងរស្មីថ្លាឱ្យអូន ខ្លោចចិត្ត។
៣- ឱ! ដងកំសត់ស្ទឹងកាត់ វាលស្រែ   រនោចចុងខែ
វាលខ្មៅ ងងឹត ស្ទឹងស្លាគូ   ជាសាក្សី ជីវិត
សូមជួយអាណិត   ដល់ស្នេហ៍ ខ្ញុំ ផងៗ៕

## ចំណោទខ្មែរ

យកតាមលំនាំចំរៀង

## ចំណោទស្នេហ៍

១- *គ្រាប់ភ្នែក ក្រឡេក ក្រឡឹត ក្រឡាប់ ហាក់បី ចង់ប្រាប់*
*ឲ្យខ្មែរ ដោះស្រាយ បើចំណោទ ខ្មែរត្រូវតែ បរិយាយ*
*សុខចិត្ត សុខកាយ បកស្រាយ ឲ្យបាន ។*
២- *វង់ភក្ត្រស្រទន់ គយគន់ ឆាកបែរ បញ្ជាក់ ប្រាប់ខ្មែរ ត្រូវតែ ក្លាហាន*
*ស្រឡាញ់ ជាតិយើង តម្កើង ភូមិឋាន មេត្រី រាប់អានសន្តាន សន្តោស ។*

បន្ទរ- *ចំណោទខេមរា ត្រូវការ លើកលែងទោស*
*ប្រមុខ ប្រមើលត្រូវ ខុស គប្បី អនុគ្រោះ លស់លា ។*

៣- *បើសិនជាខ្មែរ ខ្មែរល្អ សុចរិត សូមលោកយល់ចិត្ត ជីវិត ខេមរា*
*ដោះស្រាយចំណោទ កុំធោត ប្រាជ្ញា កុំផិត សាវ៉ាណា លោកខ្មែរអើយ ៗ*

## ចំណោទស្នេហ៍

*សំនៀងលោកស៊ិនស៊ីសាមុត*

១- នេត្រា ភ្លឺថ្លា ដូចពេជ្រ ចរណៃ ដោតជាប់ ហឫទ័យ
ឱ្យរៀម ដោះស្រាយ បើចំណោទ ស្នេហ៍មកពី ព្រេងនាយ
សុខចិត្ត សុខកាយ ដោះស្រាយ ជូនស្រី។
២- វង់ភក្ត្រស្រទន់ គយគន់ មកបង ចោទថា ទួនល្អង មានចិត្ត ប្រណី
ឆ្លើយឆ្លង តែឫក រីតនឹក បេតី បេតី ភក្តីលើស្រី គ្មានហ្មង។

បន្ទរ- ចំណោទស្នេហា ឆ្លើយថា គ្រានេះម្តង
រៀមសូម ទទួលនួន ល្អង ជាគូរួមក្តី សុខា។

៣- បើសិនជាគូ គូពី អាតីត សូមឱ្យជួបជិត ពិតដូច ប្រាថ្នា
ឱ! ចំណោទស្នេហ៍ កុំប្រែ ចិន្តា កុំផ្លាស់ វាចាណា ព្រលឹងអើយ៕

## ផ្តែផ្តាំ

យកតាមលំនាំចំរៀង

## ផ្តោះផ្តង

បន្ទរ- តាំងតែពីដើម ខ្មែរសុខសាន្ត　　ពុំដែលរំខានជនរងគ្រោះ
ព្រោះខ្មែររុងរឿងសឿងកេរ្តិ៍ឈ្មោះ　　គោរពសិទ្ធិរស់ជនដទៃ ។
ស្រី- តាំងតែពីដើម ខ្មែរសុខសាន្ត　　ពុំដែលរំខានជនរងគ្រោះ
ព្រោះខ្មែររុងរឿងសឿងកេរ្តិ៍ឈ្មោះ　　គោរពសិទ្ធិរស់ជនដទៃ ។
ប្រុស- តែតាំងពីបាក ក្រុងអង្គរ　　ខ្មែរយើងវិកវរសែនភិតភ័យ
រស់ត្រដរខ្យល់ខ្វល់រាល់ថ្ងៃ　　កសាងទឹកដីដោយលំបាក ។
ស្រី- សៀមមិនបោលក្បួនយួនមានពុត　　ខ្មែរផងស្អិតទ្រុតលុតកំសាក
សុខចិត្តក្រិក្រងំតោកយ៉ាក　　ស៊ូទ្រាំបំណាកបំណាយស្រុក ។
ប្រុស- អូនថា នេះ ក៏រិះ ត្រូវដែរ　　តែបងប្អូនខ្មែរភ័យខ្លាចទុក្ខ
ទោះបីគេប្រាំងវាយសម្រុក　　ខ្មែរតែងសំកុកលេបគ្រួសថ្ម ។

## ផ្តោះផ្តង

*សំនៀងលោកស៊ិនស៊ីសាមុត+រស់ សិរិសុទ្ធា*

បន្ទរ- តាំងតែពីតូច មិនដែលភ័យ　　ជួបភ័ក្ត្រប្រុសថ្ងៃខ្ញុំភ័យអ្វីម្ល៉េះ
សូមប្រុសចេញទៅកុំធ្វើដូច្នេះ　　ភ័យអ្វីយ៉ាងនេះណា៎ប្រុសបង។
ស្រី- តាំងតែពីតូច មិនដែលភ័យ　　ជួបភ័ក្ត្រប្រុសថ្ងៃខ្ញុំភ័យអ្វីម្ល៉េះ
សូមប្រុសចេញទៅកុំធ្វើដូច្នេះ　　ភ័យអ្វីយ៉ាងនេះណា៎ប្រុសបង។
ប្រុស- បំណាច់បំណង បងស្គាត់មក　　រកស្រីពន្លកស្រស់ន្ទួនល្អង
បើមិនអាណិតសម្លាប់បង　　តាមតែបំណងស្រីនាងចុះ។
ស្រី- រូបប្អូនសព្វថ្ងៃប្រៀបដូចផ្កា　　រូបអ្នកឧបមាដូចកន្លង់
បានឃើញផ្កាភ្លាមចូលត្រើបត្រង់　　រួចមិនបង្អង់បោះបង់ទៅ។
ប្រុស- មិនច្នោះរូប បងដូច ដំរី　　ឯរូប ទាវស្រី ដូចអំពៅ
ដំរីបានផ្អែម ពុំដែល ទៅ　　ចាកចោលអំពៅទេកល្យាណ៕

## ព្រែកទ័ល

១- ព្រែកទ័លហូរទល់ជល់ទន្លេសាប ខែប្រាំងទឹកជាប ហូរជ្រាបរហែង
ធម្មជាតិសត្វធាតុមច្ឆាចម្បែង សែនសោកសង្រែងសង្រែង
កណ្តាប កណ្តែង កណ្តុក!

២- អនាថអាណិតអនុជជ្រលង គង្គាហូរផ្សងបំណងក្រងសុខ
ភោគផលកន្សល់កន្សាយរាយមុខ បើទ្រ័ព្យផ្គាប់ចិត្តស្រណុក
ត្រូវបោរប្ញូន់ស្រុកប្របាំ ។

បន្ទរ- ទោះទាល់អ្វីៗ កុំទាល់ សម្តី ណាព្រែកទ័លណា គ្រប់គ្រា?
គ្រប់រដូវប្រាំង រដូវវស្សា ព្រែកទ័លកុំខ្វាចវាចា
ថ្វាថ្លែង ទាំងអស់ សង្ឃឹម ។

៣- **កម្ពុជាដែលខ្មែរគិតថាមិនព្រាត់** ឥឡូវសាត់ឆ្ងាយទៅ សន្ទឹម
សម្រក់ នេត្រា ដូចភ្លៀង រលឹម បើទុកជាខ្មែរញញឹម
ក៏មិន ស្រស់ ដូចគ្រាដើម ៕

## ព្រែកឯង

(ចំរៀងគំរូ)

*សំនៀងលោកអ៊ឹម សុង សឺម*

១- ព្រែកឯងនៅឆ្ងាយឃើញដាច់អាល័យ អនុស្សាវរីយ៍ ជាប់ដោយរុក្ខជាតិ
ធ្វើម្តេចនឹងបានឃើញព្រែកឯងទៀត ពិតមែនតែខ្លួនខ្ញុំឃ្លាត
តែចិត្ត នៅតែ ក្បួចទៅ។

២- ធម្មជាតិញញឹមដែលធ្លាប់រាក់ទាក់ ឥឡូវប្រែធ្លាក់ទៅជាសត្រូវ
អនុស្សាវរីយ៍ ជាប់ដោយដងផ្លូវ គិតថាពីថ្ងៃនេះទៅ
ខានឃើញព្រែកឯងទៀតហើយ។

បន្ទរ- អនុស្សាវរីយ៍ ដែលជាប់ គ្រប់ទី ហាក់ដូចឃើញគ្រាថ្មីៗ
ដើមឈើធំៗ មានម្លប់ត្រឈៃ ឮសូរតែសម្លេងរៃ
ច្រៀងថ្លែង ក្តីអស់ សង្ឃឹម។

៣- គូព្រេងដែលខ្ញុំគិតថាមិនព្រាត់ ឥឡូវរលត់ទាំងរូប ប៉ប្រឹម
ធ្វើម្តេច នឹងបាន ជួបក្តី សង្ឃឹម បើទុកជាខ្ញុំញញឹម
ក៏មិន ស្រស់ ដូច គ្រាដើម៕

## កេរជូនតា

*បន្ទរ- ការកេរជូនតាស្តារជាតិខ្មែរ ខ្មែរណាពូកែជួយខ្មែរផង*
*ផងខ្មែរត្រូវតែឈប់ខុសឆ្គង ឆ្គងនឹងគន្លងសិល្បវិជ្ជា ។*
*ស្រី- ការកេរជូនតាស្តារជាតិខ្មែរ ខ្មែរណាពូកែជួយខ្មែរផង*
*ផងខ្មែរត្រូវតែឈប់ខុសឆ្គង ឆ្គងនឹងគន្លងសិល្បវិជ្ជា ។*
*ប្រុស- ជាជនរួមជាតិឃ្លាតបាកទោស ទោសមានកំហុសព្រោះកម្មពៀរ*
*ពៀរពិឃ្លានពានទន្ទ្រានគ្នា គ្នាវែងខ្លោចផ្សាត្រាជុនជាប ។*
*ស្រី- ជាបទឹកដីកទ័ពសន្ធាប់ដី ដីទឹកនឹកភ័យសេរីភាព*
*ភាពច្បាំងគម្រាមឈាមហូរជ្រាប ជ្រាបក្រោមគំនាបគាបបំភ័យ ។*
*ប្រុស- ភ័យពិបូជួយឡួយលួចស្រុក ស្រុកខ្មែរស្រែខ្ទុកទុក្ខរាល់ថ្ងៃ*
*ថ្ងៃយប់ព្រលប់ប្រលោមព្រៃ ព្រៃយំស្តាយដីកេរជូនតា ។*

## ផ្តោះផ្តង

(ចំរៀងគំរូ)

*សំនៀងលោកស៊ិនស៊ីសាមុត+រស់ សិរីសុទ្ធា*

បន្ទរ- តាំងតែពីតូច មិនដែលភ័យ ជួបភ័ក្ត្រប្រុសថ្ងៃខ្ញុំភ័យអ្វីម្ល៉េះ
សូមប្រុសចេញទៅកុំធ្វើដូច្នេះ ភ័យអ្វីយ៉ាងនេះណា៎ប្រុសបង។
ស្រី- តាំងតែពីតូច មិនដែលភ័យ ជួបភ័ក្ត្រប្រុសថ្ងៃខ្ញុំភ័យអ្វីម្ល៉េះ
សូមប្រុសចេញទៅកុំធ្វើដូច្នេះ ភ័យអ្វីយ៉ាងនេះណា៎ប្រុសបង។
ប្រុស- បំណាច់បំណង បងស្កាត់មក រកស្រីពន្លកស្រស់ទន្ទនល្អង
បើមិនអាណិតសម្លាប់បង តាមតែបំណងស្រីនាងចុះ។
ស្រី- រូបប្អូនសព្វថ្ងៃប្រៀបដូចផ្កា រូបអ្នកឧបមាដូចកន្លង់
បានឃើញផ្កាភ្លាមចូលត្រឹបត្រង់ រួចមិនបង្អង់បោះបង់ទៅ។
ប្រុស- មិនច្នោះរូប បងដូច ដំរី ឯរូប ទាវស្រី ដូចអំពៅ
ដំរីបានផ្អែម ពុំដែល ទៅ ចាកចោលអំពៅទេកល្យាណ៕

# បុណ្យជាតិ

បន្ទរ- បុណ្យជាតិបាតជនបន្ទន់ញាតិ ញាតិទន់វាតខ្វាចគ្រប់គ្នា
គ្នាផងអឺងកងរងវេទនា នាខ្វាចក្រំគ្រារងាក្រៃ ។
ស្រី- បុណ្យជាតិបាតជនបន្ទន់ញាតិ ញាតិទន់វាតខ្វាចគ្រប់គ្នា
គ្នាផងអឺងកងរងវេទនា នាខ្វាចក្រំគ្រារងាក្រៃ ។
ប្រុស- ក្រៃលែងក្រែងលោមានបន្ទំ ឡំលាយវាយដំខ្មែររាល់ថ្ងៃ
ថ្ងៃខែជាតិខ្មែរប្រែតម្លៃ លៃលកបារមីនឹងជួយជាតិ ។
ស្រី- ជាតិយើងដើងយល់ខ្វល់ឥតល្ហែ ល្ហែល្ហើយម្វ៉ះទេវរកញាតិ
ញាតិរស់ផុះជាលរាលខ្មែរព្រាត ព្រាតព្រោងមារយាទជាតិថ្វាថ្ងៃ ។
ប្រុស- ថ្ងៃថ្នូរមិនជោរជួញអបាយ បាយមានសប្បាយងាយសម្ដី
ដីទឹករលឹកខ្មែរប្រុសស្រី ស្រីប្រុសប្រណីស្នេហាជាតិ ។

# ផ្ដោះផ្ដង

(ចំរៀងគំរូ)

*សំនៀងលោកស៊ិនស៊ីសាមុត+រស់ សិរីសទ្ធា*

បន្ទរ- តាំងតែពីតូច មិនដែលភ័យ ជួបភ័ក្ត្រប្រុសថ្ងៃខ្ញុំភ័យអ្វីម្ល៉េះ
សូមប្រុសចេញទៅកុំធ្វើដូច្នេះ ភ័យអ្វីយ៉ាងនេះណា៎ប្រុសបង។
ស្រី- តាំងតែពីតូច មិនដែលភ័យ ជួបភ័ក្ត្រប្រុសថ្ងៃខ្ញុំភ័យអ្វីម្ល៉េះ
សូមប្រុសចេញទៅកុំធ្វើដូច្នេះ ភ័យអ្វីយ៉ាងនេះណា៎ប្រុសបង។
ប្រុស- បំណាច់បំណង បងស្កាត់មក រកស្រីពន្លកស្រស់ន្ទនល្អង
បើមិនអាណិតសម្លាប់បង តាមតែបំណងស្រីនាងចុះ។
ស្រី- រូបប្អូនសព្វថ្ងៃប្រៀបដូចផ្កា រូបអ្នកឧបមាដូចកន្លង់
បានឃើញផ្កាភ្លាមចូលត្រឹបត្រង់ រួចមិនបង្អង់បោះបង់ទៅ។
ប្រុស- មិនច្នោះ រូប បងដូច ដីរ ឯរូប ទាវស្រី ដូចអំពៅ
ដីរបានផ្អែម ពុំដែល ទៅ ចាកចោលអំពៅទេកល្យាណ ៗ៚

## ខ្មែរក្រអត់បាយ

*១)ខ្មែរក្រអត់បាយក្រហាយក្រពះ　　សង្ឃឹមបន់ព្រះព្រះនៅព្រងើយ*
*ជារូបសំណាកទ្រង់ពុំអាចឆ្លើយ　　ខ្មែរក្រីក្រអើយកុំឡើយទៅឆ្ងល់ ។*
*២)ខ្មែរផងបានរស់ក៏ព្រោះតែបាយ　　អ្នកនយោបាយកុំឆ្ងាយកុសល*
*មិនបំរើខ្មែរឡប់ឡែតាមខ្យល់　　មិនលើកតម្កល់តម្កើងជាតិយើង ។*
*៣)ក្រីក្រក្រាស់ក្រែលដែលទៅបោះឆ្នោត　　មិនគួរបើឆោតទៅលើកតម្កើង*
*អ្នកមិនគិតគូរអាសូរខ្មែរយើង　　អ្នកប្រៀបដូចឈ្លើងជញ្ជក់ឈាមជាតិ ។*
*៤)ឱ!អ្នកដឹកនាំគួរលែងប្រឡំ　　លែងទៅវាយដំបង្ខំញោមញាតិ*
*សង្គ្រោះជាតិខ្មែរពូកែព្រោងព្រាត　　លែងអត់បាយទៀតខ្មែររស់បានយូរ ៕*

## សំបួរមាស

ចំរៀងគំរូ
សំនៀងលោកស៊ីនស៊ីសាមុត

១) សំបួរមាសអឺយផ្លែលាក់សន្ទឹក　　បងបួសហើយសឹកមកដណ្តឹងស្រី
អក្ខរាបងលាក់ដាក់ក្រោមក្តារកី　　កែវកុំយកប្តីមុនរដូវភ្ជុំ។
២)អកកាច់សំបុកកុកលាស់រោមថ្មី　　ទំពាំងទូលដីឫស្សីបែកគុម្ព
ដាច់ខែអស្សុជកែវពេញក្រមុំ　　ផ្ការីកជួបឃ្មុំឃុំសុំលំអង។
៣)ផ្កាដុះតាមផ្លូវរៀមមិនត្រូវការ　　ចិត្តគួចប្រាថ្នាផ្កាក្នុងរបង
ផ្កាសំបួរមាសមានម្ចាស់គ្រប់គ្រង　　ក្រពុំលើទងចាំបងថ្នមបី។
៤)ផ្កាដុះដីក្រុងមានជង់អន្ទាក់　　ផ្កាអូនមានធ្នាក់ទាក់ភ្នែកករី
ពេលបងឃើញផ្កាដូចបានឃើញស្រី　　សូមកែវប្រណីសម្តីបងផង។

# វិចិត្រសិល្បៈ

១- វិចិត្រសិល្បៈ គ្រោះថ្នាក់ធំ ឱ!ធ្លាប់មនោរម្យឥឡូវក្រៀមក្រំ
ច្រៀងយំរាល់ថ្ងៃ តាំងពីឃ្លាតទៅ
ខ្មែរនៅនឹកស្រម័យ ទន្ទឹងរាល់ពេលយប់ថ្ងៃ
ថាថ្ងើមថ្ងៃបំពេខ្មែរ ។

២- ពេលខ្មែរទុក្ខាត្រូវការអ្នក វិចិត្រសិល្បៈ អ្នកគួរបញ្ឈាក់
រួមរ័ក្សក្ដីស្នេហ៍ រស់នៅឥតគូ
គួរឲ្យអាសូរម៉្ងេះទេ ដួងចិត្តអាណិតផងខ្មែរ
ព្រោះតែរង់ចាំបម្ងើយ ។

បន្ទរ- វិលវិញរមិញរកខ្មែរ វិលមកជួបជុំរួមស្នេហ៍
បំពេខ្មែរឲ្យល្ហែល្ហើយ ទុក្ខសោកលំបាក
តោកយ៉ាកពុំស្រាកស្រាន្តឡើយ ឱ!វិចិត្រសិល្បៈអើយ
កុំកើតទុក្ខឡើយម្នាក់ឯង ។

៣- គួរណាស់វិលវិញកុំកែប្រែ វិលមកបំពេ
ដួងអារម្មណ៍ខ្មែរ ឲ្យបានរីក រាយ វិលមកព្រលឹង
ខ្មែរតែងទន្ទឹងរាល់ថ្ងៃ វិលមកបុះណាកែវបរណៃ
បើនៅអាល័យចិត្តខ្មែរ ។ ៕

# ឧត្តមដួងចិត្ត

ចំរៀងគំរូ

សំនៀងលោកស៊ីនស៊ីសាមុត

១- ឧត្តមដួងចិត្ត ជីវិតបង ឱ! ស្រស់នួនល្អងក្នុងដួងចិត្តបង
សៅហ្មងរាល់ថ្ងៃ តាំងពីឃ្លាតទៅ
ប្រុសពៅនឹកស្រម័យ ទន្ទឹងរាល់ពេលយប់ថ្ងៃ
ថាស្រីថ្ងៃមករកបង។

២- ពេលគេងរៀមគេងអោបក្តីព្រួយ រូបមួយខ្លួនមួយ ព្រួយអើយសែនព្រួយ
ព្រួយពេកកន្លង ចរចាម្នាក់ឯង
គ្មានឮសម្លេងឆ្លើយឆ្លង ដួងចិត្តអាណិតបងផង
ព្រោះតែបងនៅស្នេហា។

បន្ទរ- វិលវិញណាព្រលឹងអឺយ រាល់ថ្ងៃទុក្ខធំឥតស្បើយ
ខ្នល់ខ្នើយកើយពីរកាយា ភ្ជួយយំរកនាង
ចង្កៀងសួររកជីវ៉ា ម្ចាស់ខ្ញុំអ្នកទៅស្ថានណា
ឱ្យខ្ញុំសោកាអាល័យ។

៣- គួរណាស់វិលវិញកុំកែប្រែ វិលមករួមស្នេហ៍
ដែបងទាំងទ្វេ ចាំទទួល ថ្ងៃ វិលមកព្រលឹង
បងគេងទន្ទឹងរាល់ថ្ងៃ វិលមកចុះណាស្រស់ថ្នើមថ្ងៃ
បើស្រីនៅមេត្តាបង៕

## ឧទ្ទិសខ្មែរថែទាំបុរី

១- ព្រះអង្គទីប្រាំ ប្រចាំក្តីសុខ ជនខ្មែរគ្រប់មុខ
រង់ចាំ មើលផ្លូវ នៅតែទន្ទឹង
សុរិយាបំព្រាង យាងប្រស់ព្រលឹង ថាខ្មែរ ត្រូវតែ រំពឹង
ងងឹត សូន្យឈឹង នឹងលា អន្ធការ ។
២- ស្រយុតស្រយង់ លិចលង់ អង្គមារ ចិត្តអន្ទះសា
ក្រទិ ក្រទា ខ្វារខ្វាចបុរី
បង្គុំមុតស្រួច កួចប៉ងក្រញី ក្រសោបក្រសាលចំណី
មកធីសប្បាយ គ្មានណាយគ្មាន ក្រែង ។

បន្ទរ- ទោះទុក្ខលំបាក តោកយ៉ាក យ៉ាងណា តែចិត្តខេមរា
នៅតែស្នេហា ជាតិខ្មែរគ្នាឯង
ទោះស្លាប់ជាខ្មោច កណ្តោចកណ្តែង គ្មានខ្លាចទេ ក្តីចម្បែង
គ្មានក្រែងខ្លាចអ្វី គ្មានបិសោកសៅ ។

៣- ខ្មែរអ្នកស្នេហ៍ជាតិ មារយាទស្ល័គ្រស្មាន យោងញាតិសន្តាន
កសាងភូមិឋាន គ្រប់គ្រាតម្រូវ
បើមានអំណាច អាចឈ្នះសត្រូវ រួមគ្នាសំដៅ
ដឹកនាំខ្មែរទៅ កាន់ផ្លូវចម្រើន ៕

# គេងយោលអង្រឹង

ចំរៀងគំរូ

សំនៀងលោកស៊ីនស៊ីសាមុត

| | | | |
|---|---|---|---|
| ១- | គេងយោលអង្រឹង | ទន្ទឹងមើលផ្លូវ | ថ្ងៃលិចផុតទៅ |
| | អាសូរស្រីពៅ | នៅតែរង់ចាំ | |
| | ចំន្ទ្ររះមាត់ទឹក | នឹកអស់បណ្តាំ | រលកទន្លេគគ្រាំ |
| | ទួញយំឱ្យទ្រាំ | នឹងកម្មវាសនា។ | |
| ២- | ចង់ជួបជានិច្ច | រាល់ថ្ងៃលិចទៅ | ចង់ជួបណាស់ពៅ |
| | លង់លុះឥឡូវ | នៅតែប្រាថ្នា | |
| | ខាំធ្មេញតឹងទ្រូង | ដួងចិត្តខ្វោចផ្សា | សង្គ្រាមនៃចិត្តគ្រួសារ |
| | ប្រហារស្នេហ៍យើង | ក្នុងភ្លើងគ្មានផ្សែង។ | |
| បន្ទរ- | ទោះខ្មោះប្រវាក់ | ដាក់បងយ៉ាងណា | តែចិត្តស្នេហា |
| | នៅតែស្រវា | ហោះជួបគ្មានក្រែង | |
| | ស្លាប់ទៅព្រាត់ចុះ | ឱ្យអស់ចម្បែង | គ្មានខ្លាចទេ ដាវលំពែង |
| | តាក់តែងជាថ្មី | ជួបគ្នាណាពៅ។ | |
| ៣- | ជួបរាល់ថ្ងៃលិច | ឱ្យភ្លេចម្តេចបាន | ទូកតូចកល្យាណ |
| | ធ្លាប់ចែវកំសាន្ត | ជិតពេលយប់ជ្រៅ | |
| | បើបងជាគ្រុឌ | រត់ឆក់ឥឡូវ | បំបាំងកាយបងនិងពៅ |
| | ផុតភ្នែកសត្រូវ | រស់នៅសុខសាន្ត៕ | |

## កម្ពុជាវេទកម្ម

១- *ជីវិតកម្ពុជាវេទនាវេរកម្ម　　ប្រចាំខេមរា*
*ជារឿងខ្លោចផ្សា　　គ្មានគ្រាកំណត់*
*បាត់បង់សន្ធារ-គ្រាំគ្រាបំផុត　　គ្រប់ខ្មែរស្រយុតរន្ធត់រណ្ដំ ។*
២- *ខ្មែរធ្លាប់សុខសាន្តឥតមានកង្វល់　　អំពល់ចម្បែង*
*កណ្ដោចកណ្ដែង　　កណ្ដាលវាលធំ*
*ឥឡូវប្រណម្យ ទូលទុក្ខទួញយំ　　តែខ្មែរខិតខំ អប់រំគ្នាឯង ។*
បន្ទរ- *សូមព្រះបារមីមេត្រីយល់យោគ　　មកជួយលើកស្ទួយសិទ្ធីលោក*
*សាងលោក ផុតទុក្ខជាក់ស្តែង　　ឲ្យផុតកម្មពៀរ វេរាអន្វែង*
*វិលវល់វង្វេង　　ប្រជែងទោសពៃរ៍ ។*
៣- *អសុរាឈ្លានពានធនធានរលាយ　　ខ្វាត់ខ្វាយរលីង*
*រលស់អស់ធេង　　ក្រញែងក្រញី*
*ក្រញៅខេមរា គ្មានគ្រាប្រណី　　លែងស្ម័គ្រមេត្រី បេតិជាតិយើង ៗ៕*

## កងកម្មកងកែវ

*ចំរៀងគំរូ*

*សំនៀងលោកស៊ិនស៊ីសាមុត*

១- ជីវិតកងកម្មប្រចាំរាងកាយ　　ដោះស្រាយវាសនា
ជាមួយគ្រួសារ　　ក្នុងខ្ទមកំសត់
និរាសស្នេហា  កំព្រាបំផុត　　ស្មើរនឹងរលត់ រលាយសង្ខារ។
២- ជីវិតសុខសាន្តលើស្ថានសិរី　　ផុតក្តីងឿងឆ្ងល់
ប្រាសចាកកម្មផល　　ដែលតាមផ្ដន្ទា
កងកែវកងសុខ  គ្មានទុក្ខរាំងរា　　តែក្ដីស្នេហា  ចិន្តាខាន យល់។
បន្ទរ- សូមទេវតារក្សាទ្វីបលោក　　មកជួយលើកស្ទួយជ័យជោគ
ដល់លោក  កំពុងខ្វាយខ្វល់　　ឱ្យរួចកម្មពៀរ  វេរាកង្វល់
សូមឱ្យ បានយល់　　តែស្នេហ៍សុខសាន្ត។
៣- ទីណាសប្បាយតែងក្លាយជាទុក្ខ　　ផុតទុក្ខកើតកម្ម
ពិតដូចបណ្ដាំ　　នៃព្រះទ្រង់ញាណ
កុំលឿនហួសច្បាប់ ទម្លាប់ព្រេងលាន　　ទើបយើងឆ្លងបាន ស្ថានសុខលោកីយ៍៕

# ឆ្លុះកញ្ចក់ឆ្មេចនេត្រា

១- កាលដើមព្រះសង្ឃ　ត្រង់នឹងធម៌អាថ៌　ត្រង់ស្បង់កោរសក់
ពេលដែលទ្រង់ឆ្លុះកញ្ចក់　ទ្រង់សំឡក់ សំឡឹងផ្ទៀងផ្អង
ជឿលង់គំនិត　ជឿពិតលើបុណ្យបាបផង　ជឿថាបានដូចបំណង
អស់សៅហ្មងនៅក្នុងជាតិថ្មី ។

២- ខ្លាចអំណាចប្រេត　សង្ឃលែងសង្កេត　ឆ្លុះហេតុនានា
ក្រែងលោភានាំនូវពៀរ　ចងវេរានឹងក្រក្រី
ខ្មែរចុកចាប់ណាស់　មិនដឹងលោកម្ចាស់អសុរី　ប្រែផ្លាស់ប្រសាសន៍ថ្មីៗ
លែងស្រដីនឹងខ្មែរខ្លាចផ្សា ។

បន្ទរ- ធ្វើបាបខ្មែរចុះ　ឬចង់ទម្លុះទម្លាយឧរា　ឬផ្តាច់ជីវ៉ា
ស្រេចតែចិន្តាដែលលោកស្រឡាញ់ ចង់បាញ់ក៏បាញ់ឲ្យអស់ចិត្តទៅ ។

៣- ក្រីក្របោះឆ្នោត　ហាក់បាញ់បញ្ឆោត　នឹងរឿងកម្មផល
មិនស្មានថាស្អាងកុសល　ត្រូវតែយល់ដល់សិទ្ធិរស់នៅ
ខ្មែរសូមសច្ចា　ប្រាជ្ញាសាងលំនៅ　បំបាត់អវិជ្ជាល្ងីតល្ងង់ខ្លៅ
ទុកជាផ្លូវតម្រូវធម្មា ៕

## **ចិត្តខុសពីមុន**

ចំរៀងគំរូ

សំនៀងនារី

១- ចិត្តខុសពីមុន ដែលអូនស្មានថា សុភាពបុរស
នៅគ្រាដំបូងបង្អស់ ដែលអូនបោះបង់ចិត្តឱ្យបង
ជឿលង់គំនិត ជឿពិតថាដូចបំណង ជឿថាបានទៅលើដៃបង
អស់សៅហ្មងក្នុងជីវិតថ្មី។
២- ពាក្យផ្អែមពិរោះ ដែលអូនជឿស្មោះ ថាពាក្យស្នេហា
បានក្លាយជាពាក្យបូស្សា ដៀលអូនថាស្រីខូះប្ដី
អូនចុកចាប់ណាស់ មិនថាចិត្តបងផ្លាស់ថ្មី ស្នេហ៍អូនក្លាយជាស្ថាន អវចី
អាប់រស្មី ក្នុងភ័ព្វវាសនា។

បន្ទរ- វាយដំអូនចុះ ឬមួយក៏ប្រុសចង់ផ្ដាច់ សង្ខារ អូនក៏មិនថា
នេះជាវាសនារបស់អូនទេ ចង់ជេរក៏ជេរឱ្យអស់ចិត្តទៅ។

៣- អូនស្មានខុសហើយ ស្មានថាជាគ្រើយ សុភមង្គល
មិនស្មានថាជាថ្នាំពុល មកប្រែប្រួលជីវិតរស់នៅ
តែអូនសូមផ្ដាំ ពេលបែកពីបងទៅ កូនយើងមួយដែលគ្នារស់នៅ
នាំគ្នាទៅរកគ្រើយសុខផង។

## នឹកឃើញតែខ្មែរ

*១-   ពេលយប់ស្រម័យ   ពេលថ្ងៃរពុក ញាំុបាយ   ល្ងាចព្រឹក   នឹកឃើញតែខ្មែរ*
*រូបស្រស់បវរ បន្តក្តីស្នេហ៍   ជាតិនេះរស់ដែរគ្មានខ្មែរម្តេចបាន ។*
*២-   ផ្តាល់អើយ ផ្តាល់ខ្ទួច   ក្តួចចិត្ត បេតី  រូបស្រស់ ប្រឹមប្រិយ៍ មេត្រីរាប់អាន*
*ខ្មែរស្រឡាញ់ខ្មែរថែទាំភូមិឋាន   ជាតិនេះរស់រានមានតែស្នេហ៍ជាតិ ។*

*បន្ទរ- បែកខ្មែរច្រើនឆ្នាំ   បណ្តាំចាំនៅ  សម្តី សម្តៅនៅក្តៅថ្មីៗ*
*ខ្មែរវិលមកវិញភ្នំពេញស្រដី   កែពាក្យ សម្តី មានស្ពី វាយដំ ។*

*៣-   ឈប់  ទាក់ទងគ្នា   កុំចងពៀរខ្មែរស្រីមានគូស្នេហ៍   ខ្លាចគេប្រទ្បំ*
*ភ្នំពេញសប្បាយ   ខ្មែរក្លាយក្រៀមក្រំ  សោកស្តាយទួញយំ  ក្រំមួយជីវិត ៕*

## នឹកឃើញតែពៅ

ចំរៀងគំរូ
សំនៀងលោកអ៊ឹងសុងសីម

១-   ពេលយប់ស្រម័យ   ពេលថ្ងៃរពួក   ញាំុបាយ   ល្ងាចព្រឹក   នឹកឃើញតែពៅ
រូបស្រស់បវរ   រកស្មានមិនត្រូវ ជាតិនេះរស់នៅគ្មានពៅម្តេចបាន។
២-   ផ្កាល់អើយ   ថ្កាល់ស្រស់   លើសទេព   ធីតា   ដំណើរសង្ហារ   ឃើញភ្លឹកវិញ្ញាណ
អូនស្រឡាញ់បងកាលយើងនៅរៀន   ជាតិនេះក្រមានប្រាថ្នាតែស្រី។

បន្ទរ-   បែកអូនបីឆ្នាំ   បន្ត សិក្សា   ក្បត់ពាក្យ សច្ចាអូនមានគូថ្មី
បងវិលមកវិញអូនប្រែសម្តី   បានជាយកប្តីម៉ែស្តីបង្ខំ។

៣-   ឈប់   ទាក់ទងគ្នា   កុំចងពៀរបង   អូនមានគូគ្រង   ខ្លាចញាតិប្រទ្បំ
អូនសើចសប្បាយ   បងទុក្ខប៉ុនភ្នំ   ស្តាយណាស់រូបមុំ   ស្តាយមួយជីវិត៕

# ក្រហមថ្មីៗ

១- ក្រហមថ្មីៗ　បំភ័យខ្មែរព្រាត　បង្គំលាញាតិ
ឃ្លាតប្រទេសជាតិ　មាតុភូមិខ្មែរ　គួរតែគិត គំនិតក្តួចស្នេហ៍
យើងកើតជាខ្មែរ　ថៃជាតិកុំសូន្យ　ទាំងប្អូនបង ។
២- ទឹកដីភូមិស្រែ　**កម្ពុជាអើយ**　បើសិនបាន ឮហើយ
សូមនាំចម្លើយផ្តាំទៅខ្មែរផង ខ្មែរនៅបរទេស　មិនធ្វេសបំណង
បង់រួមបម្រុង　ចូលជួបទាក់ទង　ដោះទុក្ខជូនជាតិ ។
បន្ទរ- ខ្មែរឆ្ងាយបុរី　ក្តីនឹកស្រម័យ　អាលោះថ្ងៃអាល័យរកញាតិ
ឱ!ភ្នំពេញបំពេញមារយាទ　រក្សាការជាតិ　លើកញាតិ ឱ្យថ្កាថ្កើ ។
៣- ឃុំបាក បង្គង　បោលលំអងផ្កា　ខ្មែរប្រៀបបាន ភមរា
ហើរធ្វងសីមា　ប្រាថ្នា រស្មី　ឱ!ខេមរា ត្រូវការសេរី
ជំនូន ភ័ក្តី　ផ្តល់ជូនទឹកដី　សិរីរុងរឿង ៕

## ភ្លៀងធ្លាក់ថ្មីៗ

ចំរៀងគំរូ

សំនៀងលោកអ៊ឹង សុង សឹម

១- ភ្លៀងធ្លាក់ថ្មីៗ　ឱ្យខ្ញុំទុក្ខព្រួយ　ព្រោះតែរូបស្រីមួយ
ព្រួយអីយសែនព្រួយ　យល់តែសុបិន្ត　បរឱិនដៀវរំដួលប៉ៃលិន
យើងព្រាត់គ្នាសិន　អូនអីយអីយអូន　កុំភ្លេចបង។
២- ដីភូមិឬស្រែ　ប៉ាហ៊ីខ្ញុំ អីយ　បើអ្នកបាន ឮហើយ
សូមនាំចម្លើយផ្តាំទៅស្រីផង　បរតាំងស៊ូ　ភូមិត្រា អូរតង
ធ្លាប់នាំនួនល្អង　កំសាន្តសាសង　មុជទឹក ស្ពានយោល។
បន្ទរ- ពេលបងឃ្លាតស្រី　ចិត្តសែនអាល័យ　ថ្ងៃថ្ងើមស្រម័យឃើញតែស្រមោល
បរប៉ៃលិនសូមអូនកុំចោល　ឱ្យរៀមតែលតោល　រស់ក្នុង ភពលោកីយ៍។
៣- ទូកចាកកំពង់　លង់ចោលច្រវា　បងដូចដួង តារា
រះឡើងពេលណា　ខ្វះតែរស្មី　អូរតាវៅ បងដៅឈ្មោះស្រី
ភូមិយ៉ាត សាក្សី　ថាខ្ញុំស្នេហ៍ស្រី　ស្នេហ៍លុះអវសាន្ត៕

# ស្វាព្រាហ្មទាំងបី

| | | |
|---|---|---|
| ១- | ស្វាព្រាហ្មទាំងបី | ខ្លាចអ្វីពេកហោង |
| | ឬខ្លាចដំបង | សំពងវាយដំ ។ |



| | | |
|---|---|---|
| ២- | ខ្លាចភ្លើងឆេះខ្ទម | រញ្ញមអាស្រម |
| | តើគេបង្ខំ? | សម្ងំយកសុខ ទាំងបី! |



| | | |
|---|---|---|
| ៣- | ខ្ទប់មាត់ត្រចៀក | ពព្រៀករស្មី |
| | បិទបាំងប្រស្រី | អ្វីក៏លែងដឹង ។ |



| | | |
|---|---|---|
| ៤- | ភូមិជ្រោយចង្វា | ខ្វោចផ្សាជល់ម្ទីង |
| | យួនខ្មែរបាមប្រឹង | កូនពីងទឹកដោះ ម៉ែយើងអឺយ ។ |

បន្ទរស្ងួន

| | | |
|---|---|---|
| ១- | ដែកដោរទោរទន់ | បន្ទន់ដោយភ្លើង |
| | ដុតផ្ទះភូមិយើង | រលើងទ្រេលទ្រម ។ |
| ២- | ផ្ទះភ្លឺរន្ទាល | រង៉ាលក្រហម |
| | ដែកដោរទោរព្រម | ប្រឈមហូរទៅ ។ |
| ៣- | ដែកដោរហូរធ្លាយ | រលាយថ្មក្តៅ |
| | ធ្លាក់បាកលំនៅ | សំដៅទំនាប ។ |
| ៤- | ទំនាយខ្មែរផ្តាំ | ចំណាំរៀងរាប |
| | បង្ក្រែរូបភាព | រូបបិត្តរជ្រាប ហាមថត ៕ |



## លលកញីឈ្មោល

## ៩៩

*បំរៀងគំរូ*

*សំនៀងលោកមាស ហុក សេង*

១- លលកញីឈ្មោល　　វាបូលហៅគ្នា<br>
ព្រោះពេលសន្ធិយា　　ជិតចូលមកដល់។<br>
២- វិលរកទ្រនំ　　ធ្លាប់ទំសុខសល់<br>
ផុតទុក្ខអំពល់　　ដែលផ្តល់ឱ្យយើង ព្រាត់គ្នា។<br>
៣- កម្មកាចអាស្រូវ　　រស់នៅពីថ្ងៃ<br>
ត្រូវព្រានចង្រៃ　　ដេញតាមប្រហារ។<br>
៤- ឱ្យយើងប្រាសព្រាត់　　និរាសចោលគ្នា<br>
ដែលយើងសច្ចា　　ប្រាថ្នាសុំជួប គ្រប់ជាតិអីយ។

បន្ទរស្ទួន

១- ព្រះអើយមើលចុះ　　ព្រានមនុស្សព្រានសត្វ<br>
លួចតែបំបាត់　　ផ្លាស់ប្តូរគ្រប់ស្នៀត។<br>
២- បាញ់ញីទុកឈ្មោល　　ឱ្យរស់ចង្អៀត<br>
ម្តេចមិនពិឃាត　　ទាំងគូទៅ?<br>
៣- ស្រណោះស្រូវទុំ　　ច្រៀងសុំម្ចាស់ស្រែ<br>
ជំនោរដើមខែ　　រៀមបួលស្រែកហៅ<br>
៤- ធ្លាប់ស្តាប់សូរសៀង　　ចម្រៀងស្រីពៅ<br>
ពីថ្ងៃនេះទៅ　　ពៅអើយបងនៅ ពោះម៉ាយ៕



# ខ្លុយខ្មែរពិណាចិន

១- សៀងខ្លុយខ្មែរ　　ខ្មាសម្ចាស់ចិនទេ?
បំភ្លេចមេត្រីបទខ្មែរ　　លន្លង់លន្លោចខ្លោចផ្សា
ខ្លុយត្រលួច　　ប៉ងក្លួចចិត្តខេមរា
ចិនដេញពិណត្រាំត្រា　　ឲ្យចិន្តាត្រាំត្រេង ។

២- ខ្លុយរសាត់　　ទៅស្ងាត់សូន្យឈឹង
បេះដូងខ្មែរភ្នំពេញទន្ទឹង　　ព្រលឹងវិលវិងប្រលែង
ប្រើនបណ្ដាំ　　រាល់ឆ្នាំខ្មែរតែងចាត់ចែង
ចាត់ផ្ញើសារតាមភ្លេង　　ខ្លុយស្រស់ក្មេងមិនឆ្លើយ ។

បន្ទរ

អូ!ខ្លុយខ្មែរ　ធ្លាប់ថែខេមរា　　គួរមេត្តាបំបែងវាចា　ល្ហែល្ហើយ
សូមពិណចិន　អ្នកកុំបង្ហិន　　បង្ហោច　ក្ងិនអសោច　ខ្មោចអើយ
ខ្មោះខ្មួរខ្មាយខ្មី　ពិណរណ្ដំ　　ក្រំក្រៀមកន្ត្រាក់ ។

៣- សម្ដេងពិណ　មិនញ៉ិន　　ចង្វាក់ រលាក់រលីករាល់ថ្ងៃ
សៀងខ្លុយខ្មែរនឹងផ្លុំបំពេ　　ពិណថ្ងៃ　ប្រលោមព្រលឹងពិសី
　　ស្មោះភក្ដី　ខ្លុយចិនពិណខ្មែរ ៕

# ខ្លុយស្នេហ៍ត្នោតទេរ

១-　សៀងខ្លុយស្នេហ៍　　　ថែម្លប់ត្នោតទេរ
ទួញរៀបរាប់ប្រាប់រឿងស្នេហ៍　　　តឹងទ្រូងទូងទួញសោកា
ខ្លុយបោកខ្លួន　　　អង្រួនរកម្ចាស់សង្ខារ
ត្នោតទេរយំយោលយារ　　　ព្រោះស្នេហាឃ្លាតឆ្ងាយ។
២-　អូនទៅស្ងាត់　　　ទៅបាត់សូន្យឈឹង
បេះដូងបងសង្រេងទន្ទឹង　　　ព្រលឹងព្រាត់ឈឹងលាក់កាយ
ច្រើនបណ្ដាំ　　　ពាក្យពេចន៍រៀមផ្ដាំ
រឿងរាយចាត់ចារធ្វើចុតហ្មាយ　　　ស្រស់ឆោមឆាយមិនឆ្លើយ។

បន្ទរ-
អូ! ខ្លុយស្នេហ៍　　ធ្លាប់ថែស្នេហា　　អ្នកមេត្តា　　ច្រៀងលោមចិន្ដាត្រាណត្រើយ
សូមត្នោតទេរ　　អ្នកជួយរាំរេ　　បក់បោយ　　ស្រែកដង្ហោយ　ស្នេហ៍អើយ
　　ឱ្យស្ងួនវិលវៃ　　ទឹកត្នោតផ្អែម　　ថែមចិត្តស្មោះស្ម័គ្រ។

៣-　ម្លប់ដើមទេរ　　នៅតែត្រជាក់　　រាក់ទាក់　　រង់ចាំផ្លូវថ្ងៃ
សៀងខ្លុយស្នេហ៍នឹងច្រៀងបំពេ　　បទថ្មី　　ថ្នាក់ថ្នមចិត្តពិសី
　　　　ស្មោះភក្ដី　　ខ្លុយស្នេហ៍ត្នោតទេរ៕

# អប្សរ!

សំនៀងប្រុស

***ពោល១៖***

អប្សរ! *សូមកិន្នរទទួលអបអរសាទរនឹងចម្រៀងដូចតទៅនេះ ៖*

| | | |
|---|---|---|
| ១- | អប្សរ! *រូបកិន្នរថ្មប្រពៃ* | *ប្រឹមប្រិយ! លើកដៃលាក់សម្តីសម្ងាត់* |
| | រសាត់! *រសាប់រសល់ខ្វល់ក្នុងចិត្ត* | មិនគិត! *ដល់ជីវិតដែលស្មោះស្ម័គ្រ ។* |
| ២- | អប្សរ! *ខ្មែរសូមអង្វរស្រីឱ្យជួយ* | *ខ្លួនមួយទ្រូងមួយ ក្រៀមក្រំកំព្រា* |
| | *ខ្លោចផ្សា ប្រាថ្នាសូមអប្សរប្រណី* | *បើថ្ងៃមិនស្រដី សូមតែវាចា ។* |
| *បន្ទរ* | *ខ្មែរឈរភាំងគាំងអស់បេះដូង* | *ញាប់ញ័របំកោងឈោងចាប់តែផ្កាយ* |
| | *ខ្មែរនៅស្ងៀមមិនណាយ ដល់កាយ ស្រី* | *ថ្ងៃមិនប្រណីដួងចិត្តគ្រាំគ្រា អូ!អូ!*អប្សរ។ |
| | *រឿងអ្វីទៀតឱ្យខ្មែរភ្លេចបាន!* | *បំភ្លេចផុំផាន! មិនបាន តើរឿងហេតុអ្វី?* |
| | *សូមស្រីឆ្លើយនូវចម្លើយយ៉ាងខ្លី* | *បើថ្ងៃមិនស្រដី សូមតែវាចា ។* |

***ពោល២៖***

| | |
|---|---|
| អប្សរ! *ខ្មែរសូមអង្វរស្រីឱ្យជួយ* | *ខ្លួនមួយទ្រូងមួយ ក្រៀមក្រំកំព្រា* |
| *ខ្លោចផ្សា ប្រាថ្នាសូមអប្សរប្រណី* | *បើថ្ងៃមិនស្រដី សូមតែវាចា ។* |

***ពោលបញ្ចប់(រំលងពោល២)៖***

អប្សរ! *សូមកិន្នរកុំងរនឹងខ្មែរឱ្យសោះ ៗ*

# អានី!

*សំនៀងលោកស៊ីនស៊ីសាមុត*

ពោល១÷

អានី! ខ្ញុំនឹងច្រៀងចម្រៀងនេះដើម្បីអ្នក។

១- អានី! រាត្រីដែលរៀមបានជួបថ្ងៃ រាត្រី! ដែលនាំមកនូវក្ដីវិបត្តិ
ញាប់ញ័រក្នុងចិត្តដែលរូបស្រីមិនគិត អាណិតដល់រូបខ្ញុំលួចសម្លឹងអ្នក។

២- អានី! ពេលស្រីរាំខ្ញុំពាំទុក្ខព្រួយ ខ្លួនមួយទ្រូងរែងព្រួយក្រៀមក្រាំខ្លោចផ្សា
យ៉ាងណាប្រាថ្នាសូមតែចិត្តភក្ដី បើថ្ងៃមិនបេតីសូមស្រីមេត្តា។

បន្ទរ ខ្ញុំឈរកៀនលួចគន់ភក្ត្រា ដូចឃើញតារាដែលរះសែនឆ្ងាយ
ចិត្តរៀមនៅនឹកស្ដាយដល់កាយស្រី ថ្ងៃមិនប្រណីបេះដូងកំព្រាអូ! អូ! អានី។
រឿងអ្វីទៀតខ្ញុំភ្លេចមិនបានកល្យាណ! បំភ្លេចមិនបានតើរឿងហេតុអ្វី?
សូមស្រីឆ្លើយនូវចម្លើយយ៉ាងខ្លី បើថ្ងៃមិនបេតីសូមស្រីមេត្តា។

ពោល២÷

អានី! ពេលស្រីរាំខ្ញុំពាំទុក្ខព្រួយ ខ្លួនមួយទ្រូងរែងព្រួយក្រៀមក្រាំទុក្ខា
យ៉ាងណាប្រាថ្នាសូមតែចិត្តភក្ដី បើថ្ងៃមិនបេតីសូមស្រីមេត្តា។

ពោលបញ្ចប់(វិលងពោល២)÷

អានី! សូមស្រីកុំជិនណាយរូបបងឱ្យសោះ៕

## ភ្នែកខេមរា

សំនៀងបុរស

*១- ភ្នែកខេមរា ធ្លុះភ្លឺថ្លាថាឃើញរាក់ជ្រៅ*
*យល់ធម៌អាក្រក់ល្អសខ្មៅ ពុំអាចនិត្យនៅល្ងង់ខ្លៅ*
*តទៅទៀតបានទេ ។*
*២- ភ្នែកខេមរា ឃើញហេតុការថាត្រូវតែខ្មែរ*
*ស្នេហ៍ស្និទ្ធឥតប្រែ ជាតិមួយដែលខ្មែរខំថែ*
*ទុកជាកេរស្មោះស្ម័គ្រ ។*
*បន្ទរ- កែវភ្នែកខេមរាអើយ ភ្នែកនេះហើយដែលខ្មែរជំពាក់*
*ពេលភ្នែកបើកកាលណា ស្លុះស្លារស្វាបភ័ក្ត្រ*
*ឃើញជាក់ភ្នែកមួយ លើកស្ទួយអ្វីៗ ។*
*៣- ភ្នែកខេមរា សង្ឃឹមថា ជួបគ្នាជាថ្មី*
*ចិត្តខ្មែរនៅស្នេហ៍ប្រុសស្រី ស្នេហ៍ភ្នែក មុជជ្រែកផែនដី*
*លុះក្ស័យ ដល់ថ្ងៃអវសាន្ត ។៚*

## ដួងនេត្រា

សំនៀងរបស់លោកស៊ីនស៊ីសាមុត

១- ដួងនេត្រា មានវាចាថានៅអាល័យ
ពេលដែលរៀមត្រូវឃ្លាតឆ្ងាយ នៅនឹកស្រណោះនឹកស្ដាយ
ឥតណាយឥតបែកបែរ។
២- ដួងនេត្រា មានវាចាថានៅតែស្នេហ៍
ស្នេហ៍ឥតគេចកែ ចិត្តមួយដែលបងខំថែ
ទុកឱ្យតែអូនម្នាក់។
បន្ទរ- កែវភ្នែកដ៏ស្រស់អើយ ភ្នែកនេះហើយដែលរៀមជំពាក់
នៅពេលបងនិទ្រា ស្រម័យឃើញភ័ក្ត្រ
វរល័ក្ខណ៍ដែលធ្លាប់ញញឹមប្រឹមប្រិយ។
៣- ដួងនេត្រា សង្ឃឹមថា ជួបគ្នាជាថ្មី
ចិត្តរៀមនៅតែស្នេហ៍ស្រី ស្នេហ៍ធំ ដូច ភពផែនដី
គ្មានអ្វីមកបំបែកបាន។៚

## ត្រជាក់ចិត្តខេមរា

សំនៀងប្រុស+ស្រី

ប្រុស- ត្រជាក់ចិត្តខេមរា ព្រោះវាចាមេបាលែងឆ្គង
ត្រជាក់ចិត្តពេកកន្ទង ខ្មែរស្គាល់ចិត្តប្អូនបង
អន្ទងទឹកចិត្តខេមរា ។

ស្រី- ត្រជាក់ចិត្តផ្ដោះផ្ដង ព្រោះលែងឆ្គងគន្ទងរដ្ឋា
មិនឲ្យខ្មែរអត់អាហារ ទោះក្រីក្រខ្សត់យ៉ាងណា
មេបាមេត្តាជានិច្ច ។

ប្រុស+ស្រី- លែងជឿពាក្យបោកប្រាស ទោះថ្មីចាស់មិនភ្លេច
ប្រុស ខ្មែរធ្លាប់ដឹងយល់គ្រប់កលល្បិច
ស្រី ខ្មែរចាំជានិច្ច មិនភ្លេចទេណា ខ្មែរណា !
ប្រុស- សែនត្រជាក់ចិត្តក្រៃ នឹកស្រមៃដល់ថ្ងៃសុខា
ប្រុស+ស្រី- សុខស្មោះលុះអស់ទុក្ខា មិនកែប្រែវាចាសាវា
ចោលសុខាឡើយ ។

**ភ្លេងមួយបទចប់ទើបបន្ទរ**

ប្រុស- ត្រជាក់ចិត្តខេមរា ព្រោះវាចាមេបាលែងឆ្គង
ត្រជាក់ចិត្តពេកកន្ទង ខ្មែរស្គាល់ចិត្តប្អូនបង
អន្ទងទឹកចិត្តខេមរា ។

ស្រី- ត្រជាក់ចិត្តផ្ដោះផ្ដង ព្រោះលែងឆ្គងគន្ទងរដ្ឋា
មិនឲ្យខ្មែរអត់អាហារ ទោះក្រីក្រខ្សត់យ៉ាងណា
មេបាមេត្តាជានិច្ច ។

ប្រុស+ស្រី- លែងជឿពាក្យបោកប្រាស ទោះថ្មីចាស់មិនភ្លេច
ប្រុស ខ្មែរធ្លាប់ដឹងយល់គ្រប់កលល្បិច
ស្រី ខ្មែរចាំជានិច្ច មិនភ្លេចទេណា ខ្មែរណា !
ប្រុស- សែនត្រជាក់ចិត្តក្រៃ នឹកស្រមៃដល់ថ្ងៃសុខា
ប្រុស+ស្រី- សុខស្មោះលុះអស់ទុក្ខា មិនកែប្រែវាចាសាវា
ចោលសុខាឡើយ ។

# ត្រជាក់ចិត្ត

លោកស៊ីនស៊ីសាមុត+ ប៉ែនរ៉ន

ប្រុស- ត្រជាក់ចិត្តម៉្លេះទេ ព្រោះតែស្នេហ៍បានដូចបំណង
ត្រជាក់ចិត្តព្រោះនួនល្អង អូនស្គាល់ច្បាស់ចិត្តបង
ថាបងត្រូវការយ៉ាងណា?
ស្រី- ត្រជាក់ចិត្តកន្ទង ព្រោះតែបងចេះថ្នមស្នេហា
មិនឱ្យអូនព្រួយចិន្តា ទោះជាបងខឹងយ៉ាងណា
ក៏បងមេត្តាជានិច្ច។
ប្រុស+ ស្រី- រឿងស្នេហ៍យើងពីរនាក់ ចងចាំជាក់មិនភ្លេច
ប្រុស យើងធ្លាប់មើលសុរិយារៀបលិច
ស្រី អូនចាំជានិច្ច មិនភ្លេចទេណាបងណា!។
ប្រុស- សែនត្រជាក់ចិត្តក្រៃ នឹកស្រមៃដល់ថ្ងៃស្នេហា
ប្រុស+ ស្រី ស្នេហ៍ស្មោះលុះអស់សង្ខារ មិនកែប្រែចិន្តាសាវា
ចោលស្នេហាឡើយ។

**ភ្លេងមួយបទចប់ទើបបន្ទរ**

ប្រុស- ត្រជាក់ចិត្តម៉្លេះទេ ព្រោះតែស្នេហ៍បានដូចបំណង
ត្រជាក់ចិត្តព្រោះនួនល្អង អូនស្គាល់ច្បាស់ចិត្តបង
ថាបងត្រូវការយ៉ាងណា?
ស្រី- ត្រជាក់ចិត្តកន្ទង ព្រោះតែបងចេះថ្នមស្នេហា
មិនឱ្យអូនព្រួយចិន្តា ទោះជាបងខឹងយ៉ាងណា
ក៏បងមេត្តាជានិច្ច។
ប្រុស+ ស្រី- រឿងស្នេហ៍យើងពីរនាក់ ចងចាំជាក់មិនភ្លេច
ប្រុស យើងធ្លាប់មើលសុរិយារៀបលិច
ស្រី អូនចាំជានិច្ច មិនភ្លេចទេណាបងណា!។
ប្រុស- សែនត្រជាក់ចិត្តក្រៃ នឹកស្រមៃដល់ថ្ងៃស្នេហា
ប្រុស+ ស្រី ស្នេហ៍ស្មោះលុះអស់សង្ខារ មិនកែប្រែចិន្តាសាវា
ចោលស្នេហាឡើយ។

## ខ្លៅសោះសូន្យ

សំនៀងបុរស

១- *ខ្លៅសោះសូន្យ កូនចៅត្រី ខ្មែរណាដែលព្យួនពួនប្រហារ*
*ខ្មែរស្លាប់ហិនហោចខ្លោចផ្សា រស់ឆ្ងេរឆ្ងារត់ចោលស្រុក*
*បាត់ស្នាត់មុខទុក្ខរលឹម ។*

២- *ស្លាយសិទ្ធិសេរី ស្លាយក្តី សុខុម យំមួយលានឆ្នាំក៏ទ្រាំបានដែរ*
*តែពេលនេះខ្មែរយំគ្មានល្ហែ ខ្មែរខំទប់ទឹកនេត្រាដែរ*
*តែទឹកភ្នែកនៅហូរជដែល ។*

បន្ទរ- *ឱ!រាជអើយរាជរាស្ត្រមិនខឹងទេ រាស្ត្រមិនជេរទេនៅតែស្នេហ៍ជានិច្ច*
*ឲ្យភ្លេចមិនភ្លេច ថ្វីបើរាជមានកលល្បិច*
*ស៊ូយំសស្រិចម្នាក់ឯង ។*

៣- *ពីតូចដល់ធំខ្មែរយំគ្រាំគ្រា យំព្រោះកម្មពៀរមិនដែលយំទេ*
*តែពេលនេះខ្មែរយំឥតល្ហែ ខ្មែរខំទប់ទឹកនេត្រាដែរ*
*តែទឹកភ្នែកនៅហូរជដែល ។*

៤- *យប់នេះរាស្ត្រយំប្រាប់ជនរួមជាតិ រំលឹកដល់ញាតិកុំភ្លេចបន្ទំ*
*រាជវាចាផ្អែមជាងទឹកឃ្មុំ តែវាចាអាចឲ្យរាស្ត្រយំ*
*យំរណ្តំគ្រប់ពេលវេលា ។l*

## ជើងមេឃខ្មៅ

សំនៀងរបស់លោកស៊ីនស៊ីសាមុត

១-　ជើងមេឃខ្មៅ　ហៅលែងឮ　　ស្រីណាមិនឈឺដួងចិត្តខ្លោចផ្សា
បើប្រុសក្បត់សម្បថស្នេហា　　ហ៊ានរៀបការផ្ដើមនឹងគូថ្មី
តើសល់អ្វីឱ្យខ្ញុំសង្ឃឹម។

២-　ស្ដាយព្រហ្មចារីយ៍　ស្ដាយវ័យ ក្រមុំ　　យំមួយម៉ឺនឆ្នាំក៏មិនបាត់ដែរ
តែពេលនេះខ្ញុំយំគ្មានល្ហែ　　ខ្ញុំខំទប់ទឹកភ្នែកណាស់ដែរ
តែទឹកភ្នែកនៅហូរដដែល។

បន្ទរ-　ឱ! បងអើយបងអូនមិនខឹងទេ　　អូនមិនជេរទេនៅតែស្នេហ៍ជានិច្ច
ឱ្យភ្លេចមិនភ្លេច　　ថ្វីបើប្រុសមានកលល្បិច
ស៊ូយំសស្រិចម្នាក់ឯង។

៣-　ពីតូចដល់ធំខ្ញុំយំធម្មតា　　យំព្រោះស្នេហាមិនដែលយំទេ
តែពេលនេះខ្ញុំយំឥតល្ហែ　　ខ្ញុំខំទប់ទឹកភ្នែកណាស់ដែរ
តែទឹកភ្នែកនៅហូរដដែល។

៤-　យប់នេះខ្ញុំយំស្រែកប្រាប់ធម្មជាតិ　　ប្រាប់ស្រីឯទៀតកុំឱ្យដូចខ្ញុំ
មែនស្នេហាផ្អែមជាងទឹកឃ្មុំ　　តែស្នេហាអាចឱ្យយើងយំ
យំមិនបាត់អស់មួយជីវិត៕

## **ពើតផ្សា**

សំនៀងបុរស

១- *ពើតអ្វី មិនស្មើ ពើតផ្សា        បុកឧរាខេមរាកំសត់*
*ក្រិក្រខ្សត់ខ្សោយតើឲ្យអំណត់        អំណាចអំណោយក៏អត់*
*ទ្រាំខ្សត់សង្កត់ចិត្តកន្លល់?*

២- *ក្រហម ក្រញូមកម្មោច        ក្លិនហិនហោចក្រហាយក្រហល់*
*កុហកពិចិនហូរហៀរទៅដល់        យួនក៏សោកស្តាយខ្វាយខ្វល់*
*អំពល់ចិត្តសន្តាន ។*

បន្ទរ- *ពាក្យសង្ឃពាក្យសត្យ ប្រយ័ត្នប្រយែង        ពិតស្មែងវែងរំខាន*
*បើសិនពាក្យពុលជ្រុលជ្រួសសាមាន្យ        នាំឲ្យខ្មែរស្លាប់វិនាសអន្តរធាន*
*រងកម្មក្ស័យប្រាណធ្លាក់ឋានអវិចី ។*

៣- *ពើតផ្សាគឺ ពើតខ្មោចផ្សា        នាំឧរាខេមរាវិនាស*
*បើ រោយគឺ រោយដោយសារវេចី        ទុច្ចរិតប្រព្រឹត្តថ្មមថី*
*រំលោភមេត្រីចិត្ត ៕*

# ព្រួញស្នេហ៍

សំនៀងរបស់លោកស៊ីនស៊ីសាមុត

១- ព្រួញអ្វី មិនស្មើ ព្រួញស្នេហ៍ ចាញ់រកតែរង្វង់បេះដូង
ត្រូវហើយឈឺចាប់ពេញណែនដើមទ្រូង ដំបៅជ្រៅដូចអណ្តូង
ស៊ីរូងថ្លើមប្រមាត់គ្មានសល់។
២- ព្រួញស្នេហ៍ គឺ ព្រួញកំណាច ត្រូវតែខ្លាចបើមិនទាន់ស្គាល់
បើស្នេហ៍មិនទាន់រិះគិតឱ្យដល់ មុខជាមានក្តីកង្វល់
មកដល់ចិត្តមិនខាន។

បន្ទរ- សម្តីដែលផ្អែម ពិរោះ ពិរោះ គឺជឿថាចិត្តបង
នោះហើយគឺជាព្រួញស្នេហ៍សាមាន្យ បើដឹងមុនហើយកុំយកដៃកាន់
ខ្លាចក្រែងខកប្រាណព្រោះស្នេហ៍អប្រិយ៍។

៣- ព្រួញស្នេហ៍គឺ ព្រួញពិសពុល បើបានយល់មុខតែរីងរៃ
បើ ស្លាប់ គឺ ស្លាប់ ព្រោះតែសម្តី ថ្នាក់ថ្នមល្បួងលោមចិត្តស្រី
ឱ្យប្រគល់ក្តីស្នេហ៍៕

## **កម្មឯងព្រេងគេ**

សំនៀងបុរស

*១- កម្មឯងព្រេងគេបំពេជូរជួប បូរាណបានលួចលាក់ពីបុព្វ*
*កម្មឯងព្រេងអញគួរកាញ់គ្នាន់គ្នេរ តើខ្មែរត្រូវតែយល់របៀបណា?*
*២- ស្រណោះស្រណោកយំសោកបោកខ្លួន ភ័យខ្លាចតែយួនពួនពួយរដ្ឋា*
*អាណិតព្រៃឈើផុះលើបព្វតា រាប់សែនហិកតាកាប់ឆ្ការហ្មត់ហ្មង ។*

*បន្ទរ- ខេមរាសប្តាវៀរបោកគ្រោះថ្នាក់ ធ្ងន់ដូចថ្មបាក់ធ្លាក់មកលើខ្នង*
*ចុះទឹកក្រពើឡើងលើខ្លាផង ទោះខ្មែរប្រុងធ្លងពុំរួចឡើយណា ។*

*៣- សាកលលោកជួយជំនួយសង្គ្រោះ ឲ្យខ្មែរមានឈ្មោះរស់ក្នុងលោកា*
*សូមខ្មែរបោកទុក្ខសាងសុខនឹងគ្នា កសាងកម្ពុជាលុះគ្រាសុខសាន្ត ៕*

## **គេងព្រួយតែឯង**

សំនៀងរបស់លោកស៊ីនស៊ីសាមុត

១- គេងព្រួយតែឯងរកថ្លែងពុំរួច ព្រោះស្នេហ៍លាក់លួចលបស្រឡាញ់គេ
ព្រួយខ្លាំងទុក្ខខ្លាំងព្រួយគ្មានទំនេរ តើឱ្យខ្ញុំរេគិតរបៀបណា?
២- ព្រួយខ្លាំងទុក្ខខ្លាំងភ័ន្តភាំងក្នុងចិត្ត ព្រោះក្តីស្នេហ៍ពិតគេឥតមេត្តា
ប្រាសខ្នងគងខ្នើយគេងកើយហត្ថា ឃើញតែភក្ត្រាស្រស់នៅមុខបង។

បន្ទរ- យល់មុខទុកមកដូចជាគេដាក់ ធ្ងន់ឡើងឥតស្រាកសោះឡើយន្ទនល្អង
បានឃើញភ័ក្ត្រស្រីអស់ក្តីសៅហ្មង តើឱ្យខ្ញុំប៉ងគិតរបៀបណា?

៣- តើធ្វើម្តេចទៅទើបពៅយល់ចិត្ត ថាស្នេហ៍ពិតស្នេហ៍ឥតមុសា
រយទុក្ខរយព្រួយរាល់ពេលវេលា សច្ចាបន់ស្រន់សូមជួបគ្រប់ជាតិៗ៕

## ដូងទេរទៅលិច

សំនៀងបុរស

១- ដូងទេរទៅកើតដូចមិនកើតទេ ព្រោះខ្មែរតែងតែគោរពព្រះ(ពីរដង)
ព្រះបែរទៅកើតអើតទតថ្ងៃរះ ដូងមិនត្រូវឈ្នះលើព្រះពុទ្ធអង្គ ។
២- ដើមដូងដុះទេរទៅទិសខាងលិច ពុំមែនជាល្បិចល្បែងលេងខុសគ្គង(ពីរដង)
ដូងអើយដុះទេរជួយរេអន្ទង ឧបត្ថម្ភគ្រប់គ្រងបម្រុងខេមរា ។

បន្ទរ- អាសូរយប់ស្ងាត់ខ្យល់ផាត់រំភើយ ក្រអូបបង្ហើយក្លែបក្លិនជីវ៉ា
ក្លិនផ្កាចំប៉ីក្លិនផ្កាចំប៉ា រំដួលក្តាំងផាការពារថៃជាតិ ។

៣- គូខ្មែរ ត្រូវតែតស៊ូរងកម្ម គាំទ្ររាល់ឆ្នាំប្រចាំសាងជាតិ (ពីរដង)
បានកើតជាខ្មែរមិនបែរពីញាតិ ក្បត់ជនរួមជាតិមារយាទមាយា ៗ

## ដើមដូងព្រលឹងស្នេហ៍

សំនៀងរបស់លោកស៊ីនស៊ីសាមុត

១- ឱ! រាត្រីស្ងាត់នាមាត់ទន្លេ កន្លែងគូស្នេហ៍ធ្លាប់មកកំសាន្ត(ពីរដង)
អង្គុយរៀបរាប់រឿងស្នេហ៍ពីរប្រាណ ក្រោមដូងព្រះច័ន្ទ្រដែលរះពេញវង់។
២- ដើមដូងដុះទេរទាបទៅមាត់ស្ទឹង ជាដួងព្រលឹងខ្ញុំ និង ទួនល្អង(ពីរដង)
ដូងអើយដុះទេរកុំរេសៅហ្មង ជួយចាំខ្ញុំផងចាំរឿងស្នេហា។

បន្ទរ- យប់យន់ត្រជាក់ខ្យល់ធ្លាក់រំភើយ ក្រអូបបង្ហើយក្លែបក្លិនកនិដ្ឋា
ក្លិនផ្កាចំប៉ីក្លិនស្រីសាវ៉ា ជីវិតស្នេហាប្រាថ្នាគ្រប់ជាតិ។

៣- គូខ្ញុំ បើព្រាត់គឺព្រាត់ដោយកម្ម មិនមែនចិត្តនាំឱ្យខ្ញុំឃ្លាងឃ្លាត(ពីរដង)
ជាតិនេះជួបហើយជាតិក្រោយជួបទៀត សូមជួបគ្រប់ជាតិមិនឃ្លាតសោះឡើយ៕

## ជម្រកខ្មែរ

សំនៀងបុរស

១- *ជម្រកជម្រុកសម្បុកខ្មែរ* | *សម្បត្តិជ្រាលជ្រៅទេរទៅខាងកើត*
*កំណាន់គំនិតពិតប្រឹងតែអើត* | *ប្រុងធក់ឲ្យធើតធាប់ប្រណិត ។*
២- *ក្រហមក្រហល់ក្រហាយខ្លាំង* | *ចោទយួនថាខ្លាំងចូលមកជម្រឹត*
*ខ្មែរណាដែលព្យួនពួនប្រព្រឹត្ត* | *មិនស្រង់ជីវិតដោយប្រណី?*

បន្ទរ- *ខ្មែរសូមសច្ចាចំពោះមុខ* | *មានព្រះប្រមុខជាសាក្សី*
*បើខ្មែរមិនស្មោះស្ម័គ្រមេត្រី* | *សូមព្រះប្រល័យខ្មែរចោលទៅ!*

៣- *ឱ!ជម្រកខ្មែរកុំប្រែចិត្ត* | *កុំក្បត់គំនិតពិតជាសត្រូវ*
*សូមបងប្អូនខ្មែរជួយតម្រូវ* | *បើកផ្លូវឲ្យខ្មែរថែសុខសាន្ត ៕*

## កំពង់ធំជំរំចិត្ត

សំនៀងរបស់លោកស៊ីនស៊ីសាមុត

១- នេះគឺសំណាងយ៉ាងចំណាន | ដែលវាសនាបាន នាំឱ្យរូបខ្ញុំ
ចាប់ចិត្តផ្សងបំណងលើមុំ | ឱ! កំពង់ធំថ្លើមជីវិត។
២- រស់ក្លិនក្រអូបជ្រាបសព្វប្រាណ | ត្រជាក់ប្រៀបបាននឹងទឹកអម្រឹត
កែវអើយសូមស្ងួនទួននាងអាណិត | ស្រោចស្រង់ជីវិតដោយប្រណី។

បន្ទរ- រៀមសូមសច្ចាចំពោះមុខ | មានភ្នំសន្ទុកជាសាក្សី
បើខ្ញុំមិនស្មោះចំពោះស្រី | សូមអ្នកប្រល័យខ្ញុំចោលទៅ។

៣- ឱ! កំពង់ធំជំរំចិត្ត | សូមធ្វើជីវិតរឿងពិតនឹងពៅ
សូមស្ទឹងព្រៃប្រស់ជួយថែចូវ | រូបពៅឱ្យខ្ញុំជាគូអើយ៕

## ឧរាអ្នួលណែន

សំនៀងបុរស

១- ឧរាអួលណែន ចុកណែន តើតផ្សា យ៉ាងនេះ    បងប្អូនជួយត្រិះរិះពិចារណា
អាសូរខ្មែរពេកមុជជ្រែកគគ្គា    ដោយពុំដឹងថាគគ្គាត្រជាក់ ។
២- រងាខ្លាំងណាស់ណាម្ចាស់ទឹកថ្លាអម្រឹត    អង្រួនជីវិតឲ្យខ្មែរញ័រញាក់
ស្រឡាញ់ខេមរាប្រាថ្នាស្មោះស្ម័គ្រ    ទោះជាប្រវាក់ទាក់កដល់ដី!

បន្ទរ- ឥឡូវបើខ្មែរងាករេទៅកើត    ឲ្យស្រុកខ្មែរធើតបានដែរឬអ្វី?
ធម្មជាតិប្រែប្រួលរម្មលទឹកដី    រលស់ព្រឹក្សព្រៃត្រីសត្វនានា ។

៣- ទោះយួនក្របហមពួនពមទំពាបុរី    បងប្អូនកុំបីអាប់អោនប្រាជ្ញា
លង់លុះល្ងឹតល្ងង់ល្ងិល្ងើវិជ្ជា    នាំនូវវេរាគ្គន្ធាដល់ខ្មែរ ៗ

## តឹងទ្រូងខ្លាំងណាស់

សំនៀងរបស់លោកស៊ីនស៊ីសាមុត

១- តឹងទ្រូងខ្លាំងណាស់ គួរខ្មាស គួររាង គួរខ្លាច    ជួនជោរជួននាចឥតពិចារណា
អាសូរខ្លួនពេកវែកពុនស្នេហា    ដោយជឿជាក់ថា ស្នេហាបរិសុទ្ធ។
២- ខំស្ម័គ្រខំស្មោះមិនហ៊ានឱ្យទាស់មួយគ្រា    មិនខ្លាចវេទនា មិនរាពិរុទ្ធ
ស្នេហ៍លើពុំងាគ្មានគ្រាបំផុត    គ្មានពេលរលត់រលាយទេស្រី។

បន្ទរ- ឥឡូវបើថ្ងៃប្រែរះខាងលិច    តើឱ្យខ្ញុំធ្មេចបានដែរឬអ្វី?
ធម្មជាតិប្រែខុសក៏ព្រោះតែស្រី    កុំតូចចិត្តថ្វីនឹងន័យវាសនា។

៣- ទោះចំណងតឹងក៏ប្រឹងបម្រះឱ្យ បាន    កុំឱ្យក្ស័យប្រាណក្នុងជ្រោះតណ្ហា
កាត់សាច់មួយដុំបោះចោលឱ្យខ្លា    ឱ្យតែអាត្មាផុតកម្មពៀរអើយៗ៕

## អនិច្ចាផ្ការលាន់

*សំនៀងគំរូ*

*លោកស៊ិនស៊ីសាមុត*

១- អនិច្ចាផ្ការលាន់គគ្រឹក គេងនឹកមមៃ ទៅស្រីព្រលឹង(ស្ងួន)
កាលពីដើម ធ្លាប់ជួបគ្នាមាត់ស្ទឹងស្រីភ្លេចទេដឹង នៅក្រោមដើមជាលា។
២- ចាយកញ្ចប់ប្រហុកកប់ឆ្ងាញ់ពីសា យើងពីរកាយារាក់ទាក់ប្រិមប្រិយ៍
មិនភ្លេចទេអនុស្សាវរីយ៍ ឆ្លាក់ក្នុងហឫទ័យ ឥតអ្វីមកបំភ្លេចឡើយ។

បន្ទរ ឱ! ស្ទឹង អ្នកវែងអន្លាយ បត់បែនសែនឆ្ងាយ ឆ្ងាយដូចចិត្តស្រី(ស្ងួន)
ចិត្តសង្ឃឹមញញឹមទុករាល់ថ្ងៃ ស្រាប់តែចរណៃមានថ្មីចោលបង។

៣- មិនថ្វីទេ ណាកែវស្នេហ៍ស្នង ជាតិនេះខុសម្ដងបងសូមលាស្រី
កុំទុកចិត្តមនុស្សក្នុង លោកិយ៍ បត់បែនរាល់ថ្ងៃ ចិត្តពីរបីប្រែក្លាយមិនទៀង៕

## កុំទុកចិត្តមេឃ

សំនៀងបុរស

១- *កុំទុកចិត្តមេឃខ្ពស់ឆ្ងាយ ឃើញផ្កាយលន្ទឹម សង្ឃឹមលើអ្វី (ស្ងួន)*
*ខ្មែរតែងតែ ទុកចិត្តលោកសេរី ដឹកនាំផែនដី ឲ្យមានក្ដីល្ហែល្ហើយ ។*
២- *កុំលង់ទ្រនេសទុកចិត្តបរទេសឡើយ ខ្មែរកុំព្រងើយទាំងប្រុសទាំងស្រី*
*កុំទុកចិត្តអភិនេស្រ្កម៍អី កុំក្បត់សម្ដី ស្រដីវាចាតោះតើយ ។*

បន្ទរ *ឱ! មេឃ អ្នកវែងអន្ទាយ នៅខ្ពស់សែនឆ្ងាយ ឆ្ងាយពីផែនដី (ស្ងួន)*
*ចិត្តសង្ឃឹមញញឹមទុករាល់ថ្ងៃ ស្រាប់តែមេឃថ្មីផ្លាស់ក្ដីបំណង ។*

៣- *មិនថ្វីទេ ណាមេឃស្នេហ៍ស្នង ជាតិនេះផ្ដាំផ្ដងរងទោសព្រោះស្ដាយ*
*កុំទុកចិត្តមេឃកុំទុក ចិត្តក្លាយ ស្រីគ្មានសាហាយ ម្ដាយឯណាថាគ្មានបំណុល ៕*

## ចង់កើតជាទឹក

*សំនៀងគំរូ*

*លោកស៊ិនស៊ីសាមុត*

១- តើដឹងឬទេអ្នកណា មើលស្រី? ល្មួចមើលរាល់ថ្ងៃស្រីហែលទឹក
គឺបងនេះហើយទាំងល្ងាចទាំងព្រឹក មើលទាល់តែគេងស្រមៃនឹក ខូចចិត្តអស់ទៅហើយ។
២- សាច់សល្អខ្ចីសក់វែង ប្រាស្នា ហត្ថាហែលផងក្បូង់ទឹកលេងផង
ចង្កេះក៏តូចថ្ពាល់ខួចទាំងសង អូនបង្ហាញឱ្យឃើញសាច់ខ្នង បងរឹតតែខ្វាយខ្វល់។

បន្ទរ ចង់ហែលទឹកលេងបន្ទែងនឹងស្រី តែគ្មាននិស្ស័យដូចចិត្តប៉ងទេ
ទឹកអូនទឹកផ្ទះខុសទឹកទន្លេ បានត្រឹមតែ ល្មួចមើលអូនហែលលេង។

៣- មើលយូរៗទៅមិនចង់ ឱ្យឃ្លាត ចង់តែចាប់ជាតិកើតជាទឹក
ឱ្យអូនហែលលេងទាំងល្ងាចទាំងព្រឹក តែធ្វើម្តេចបានកើតជាទឹក អស់សង្ឃឹមហើយខ្ញុំ ៗ៕

## ចង់កើតជាដី

សំនៀងបុរស

១- *តើដឹងឬទេនរណា ប្ជូនដី? ល្មួចប្ជូនរស្មីនៅព្រៃព្រឹក្ស*
*ជីវិតសត្វផងយ៉ាងច្រើនសន្ធឹក បក្សីបក្សាមច្ឆាម្រឹគ នឹកលែងឃើញទៅហើយ ។*
២- *ជាតិខ្មែរឧត្តមមានព្រំ សីមា រដ្ឋាគ្រប់គ្រង គ្រងសិរីផង*
*ស្មោះស្ម័គ្រខេមរារក្សាប្អូនបង លើកសាសនាក្សត្រាកន្ទង ឆ្លងកាត់វាលកម្មផល ។*

បន្ទូរ *ចង់តែរក្សាការពារទឹកដី តែគ្មាននិស្ស័យដូចចិត្តប៉ងទេ*
*ទឹកដីខ្មែរខុសពីទឹកដីគេ បានត្រឹមតែ ស្រមៃស្នេហ៍ម្នាក់ឯង ។*

៣- *បើដីជាមេទឹកទេរ ជាបា ចិត្តចង់ប្រាថ្នាចាប់ជាតិជាដី*
*ឲ្យខ្មែរដើរលេងទាំងយប់ទាំងថ្ងៃ តែធ្វើម្តេចបានកើតជាដី អស់សង្ឃឹមហើយខ្ញុំ ៗ៕*

# ទឹកស្ទឹងកម្បុត

*សំនៀងតំរូ*

*លោកស៊ិនស៊ីសាមុត*

១- ឱ! ទឹកហូរ ឱ! ទឹកហូរ ហូរក្រោមស្ពាន
ប្រៀបហាក់ដូចដួងវិញ្ញាណ បងបាន ចាកប្រាណចេញទៅ
ស្វែងរកគ្រប់ផ្លូវ ខំស្វែងរកពៅ ស្វែងរកពៅ ស្វែងរកពៅ គ្រប់ពេលវេលា។
២- ទឹកហូរទៅ ទឹកហូរទៅ គ្មានឈប់ឈរ
ដូច ចិត្ត បងនៅស្មោះសរជានិច្ច គ្មានភ្លេចមួយគ្រានឹងដួងចន្ទ្រា
សូមផ្ញើវាចា ផ្ញើវាចា តាមគង្គា ទៅចន្ទ្រាផង។

បន្ទរ- ឱ! ស្ពានអើយ ទីនេះហើយ ទីនេះហើយ ទីនេះហើយ
ដែលខ្ញុំបាន នាំកល្យាណ កំសាន្ត ម្តង។
ស្តាប់ទឹកហូរ សូរឆ្លើយឆ្លង ក្រោមស្ពានកម្បត់។

៣- ឱ! ទឹកហូរ ឱ! ទឹកហូរ ហូរក្រោមស្ពាន
ប្រៀបហាក់ដូច ដួងវិញ្ញាណ បងបាន ចាកប្រាណ ចេញទៅ
ថ្នាក់ថ្នមពាលពៅ ឱ្យគេងកើយភ្លៅ គេងកើយភ្លៅ គេងកើយភ្លៅ
ក្បែរស្ទឹងកម្បុត ក្បែរស្ទឹងកម្បត់ ក្បែរស្ទឹងកម្បត់៕

## ទឹកដីកម្សត់

*សំនៀងបុរស*

១- ឱ! ទឹកដី ឱ! ទឹកដីខ្មែរ ក្បែរព្រំ
ប្រៀបហាក់ដូចរងទុក្ខធំ ខ្មែរយំ រង៉ុំរង៉ូវ
រំពៃប្រផ្នូវ ខំស្វែងគ្រប់ផ្លូវ ស្វែងគ្រប់ផ្លូវ ស្វែងគ្រប់ផ្លូវ គ្រប់ពេលវេលា ។

២- ទឹកដីខ្មែរ! ទឹកដីខ្មែរ! ថៃជំហរ
ដូចចិត្តខ្មែរនៅស្មោះសរ ជានិច្ច គ្មានក្បួចមួយគ្រានឹងជួនរង្គា
សូមផ្ញើវាចា ផ្ញើវាចា តាមបក្សា ទៅខេមរាជង ។

បន្ទរ- ដីខ្មែរអើយ! ទីនេះហើយ ទីនេះហើយ ទីនេះហើយ
ដែលខ្ញុំបាន នាំកល្យាណ កំសាន្ត ម្តង ៗ
មើលបក្សា សាសងផង លើមែកកម្សត់ ។

៣- ឱ! ទឹកដី ឱ! ទឹកដីខ្មែរ ក្បែរព្រំ
ប្រៀបហាក់ដូចរងទុក្ខធំ ខ្មែរយំ រង៉ុំរង៉ូវ
បំពេពាលពោ ឲ្យគេងកើយភ្លៅ គេងកើយភ្លៅ គេងកើយភ្លៅ
លើដីកម្សត់ លើដីកម្សត់ លើដីកម្សត់ ៗ

## ចង់យល់តែភ័ក្ត្រអូន

*សំនៀងគំរូ*

*លោកស៊ិនស៊ីសាមុត*

១- ចង់ត្រឹមតែឃើញភ័ក្ត្រអូន មិនបានខ្លួនក៏ហីទៅចុះ ចង់ត្រឹមតែឃើញសម្រស់
រូបនាងមិនដែលឃើញសោះ ស្រស់អីយស្រស់ម្ល៉េះទេ។
២- ចង់ត្រឹមតែឃើញដំណើរ រាងស្រីដើរក៏សមលើសគេ បុណ្យអ្វីសាងពីបុព្វេ
បានជាជាតិនេះមានស្នេហ៍ ឱ្យគេវង្វេងគ្រប់គ្នា។

បន្ទរ- ឃើញភ័ក្ត្រមួយដង អស់ក្តីសៅហ្មងមួយគ្រា បើឃើញរាល់ថ្ងៃ
ហាប្ញទ័យកំព្រា ក្លាយជាវិមានសុវណ្ណ។

៣- ចង់ត្រឹមតែឃើញនេត្រា រស្មីថ្លាដូចរស្មីច័ន្ទ្រ បើសិនជាលូកដៃកាន់
ដួងចិត្តបងមានប៉ុន្មាន ជូនកែវកល្យាណទាំងអស់៕

## ចង់យល់តែស្ម័គ្រភក្តិ

*សំនៀងបុរស*

*១- ចង់ត្រឹមតែស្ម័គ្រភក្តិ មិនមេត្រីក៏ហីទៅចុះ ចង់ត្រឹមតែឃើញក្តីស្មោះ*
*ទោះបីស្រីមិនស្រណោះ ឥតអាលោះក្តីស្នេហ៍ !*
*២- ចង់ត្រឹមតែឃើញទង្វើ ស្រស់ស្រីធ្វើប្រសើរជាងគេ ពុំគួរសំណាងសាងពីបុព្វេ*
*បណ្តាលឱ្យនារីខ្មែរ ប្រួលប្រែរងទុក្ខគ្រប់គ្រា ?*

*បន្ទរ- ស្មោះស្ម័គ្រប្អូនបង សំរេចបំណងគ្រប់គ្នា បើសិននិស្ស័យ*
*ប្រស្រ័យពឹងគ្នា សច្ចាគាំពារកំណាន់ ។*

*៣- ចង់ត្រឹមតែឃើញខេមរា រស្មីថ្លាដូចរស្មីចន្ទ្រ បើសិនខ្មែរមិនប្រកាន់*
*រាក់ទាក់ឥតបីប្រប័ណ្ឌ ជារឿងសំខាន់ជីវិត ៕*

## ចំប៉ីសៀមរាប

*សំនៀងគំរូ*

*លោកស៊ិនស៊ីសាមុត*

១- ឱ! ខេត្តសៀមរាបប្រៀបស្ថានឧសថ  កាលខ្ញុំប្រតិព័ទ្ធផ្កាចាត់ដំបង
ដកចិត្តពុំរួចគួចគិតគេងផ្សង  តែចាត់ដំបងចង់ស្នេហ៍គ្រចម្ប៉ា។
២- ឥឡូវបានយល់ចំប៉ីសៀមរាប  ក្រអូបជ្រួតជ្រាបពោរពេញឱរា
រូបបងបានស្បើយ ខ្សោយពីឱរា  តែផ្កាចំប៉ា ឱ្យរៀមក្រៀមក្រំ។

បន្ទរ- រយព្រួយរយនឹក រយសែនទទ្នឹង  ពុំឃើញដំណឹងដែលរៀមផ្ដែផ្ដាំ
កន្លងផុតទៅជាយូរខែឆ្នាំ  តើឱ្យទ្រាំចាំ ទ្រាំចាំ ទ្រាំចាំ ម្ដេចទៅ?

៣- ពេលនេះចំប៉ីសៀមរាបបងអើយ  មានតែអ្នកហើយព្រះលោកតម្រូវ
ជួយផងគ្រាន់ឱ្យបងបានរស់នៅ  ជាគ្នាតទៅនឹងចំប៉ីអើយ៕

## រំដួលអង្គរ

*សំនៀងបុរស*

១- *រំដួលសៀមរាបជ្រាបក្នុងឱរា  កាលខ្មែរយាត្រាប្រាថ្នាកាត់ធ្ងន់*
*រំដួលអង្គរឈរជួយចម្ងន់  ឱ្យខ្មែរយើងផងធ្ងន់រួចជីវា ។*
២- *ឥឡូវបានយល់រំដួលអង្គរ  មានចិត្តអបអរសាទរខេមរា*
*ខ្មែរយើងវិលវិញរមេញចិន្តា  ស្មោះស្ម័គ្រធម៌អាចជ្រះថ្លាឧត្តម ។*

បន្ទរ- *សែនព្រួយសែននឹក សែនគិតសញ្ជឹង  ពុំយល់ដំណឹងស្លូតស្លឹងសម្ងំ*
*បើសង្គ្រោះខ្មែរកុំបែរបង្ខំ  កុំឱ្យប្រទ្បំ ប្រទ្បំ ប្រទ្បំ ខុសត្រូវ?*

៣- *រំដួលអង្គរគាំទ្រខ្មែរហើយ  នៅគ្មានបម្រើយពីមេត្រឹមត្រូវ*
*ជួយទេគ្រាន់ឱ្យខ្មែរបានរស់នៅ  ជាគ្នាតទៅនឹងរំដួលអើយ ៕*

## មេឃមីរស្រទុំ

*សំនៀងគំរូនារី*

*ពោល ៖* មេឃមីរស្រទុំ ពពកជុំជិតរាយគ្នា*នេះជាសូរសៀងដើមផ្ញើមគំនិតក្នុងកវីនិពន្ធន៍របស់លោក*ជុំកែម *អតីតនិស្សិត*ក្រុងប៉ារីស៍*ដែលត្រូវបានសំនៀងនារីបន្ថែមន័យត្រឹមថា*មេឃមីរស្រទុំ ៗ

*មេឃមីរស្រទុំ ខ្មែរយំមិនចេញ តើនឹងបានចំណេញដល់អ្នកណា?*

*គេថា៖* បើគ្មានថ្ងៃ៧ មករា១៩៧៩ ទេក៏គ្មានថ្ងៃនេះដែរ។

*ចុះថ្ងៃ២៣តុលា១៩៩១ លើកស្ទួយដោយ*សន្និសីទនៃក្រុងប៉ារីស៍*ដើម្បីបង្រួបបង្រួមខ្មែរ តើនឹងមានន័យយ៉ាងណាទៅវិញ?*

*មានតែយោបល់ល្អប្រកបដោយគតិយុត្តិធម៌របស់បងប្អូនរួមជាតិខ្មែរទេ ដែលអាចផ្តល់តម្លៃថ្លៃថ្លាដល់ការដោះស្រាយបញ្ហាខ្មែរឲ្យរួចផុតពីក្រញាំក្រុងមារ ៗ*

| | | |
|---|---|---|
| ១- | ពេលមេឃស្រទុំ អូនយំស្រណោះ | ដួងចិត្តក្រៀមក្រោះ |
| | អស់ហើយសេចក្តីសង្ឃឹម | ព្រិលអស់កែវភ្នែកដូចភ្លៀងរលឹម |
| | ចំន្ទ្រក៏លែងញញឹម | ដូចគ្រាដើមទៀតហើយ។ |
| ២- | ចំន្ទ្រអើយដឹងទេតើមកពីអ្វី? | បានជារូបស្រី |
| | បីដូចជាទូកគ្មានត្រើយ | កាលអូនសួរបង បងក៏មិនឆ្លើយ |
| | គ្មានអ្នកណាមួយឡើយ | អាចឆ្លើយប្រាប់អូនបាន។ |
| បន្ទរ- | ដួងចិត្តហ្មងសៅរស់នៅកំព្រា | ស្នេហាឥតមានជំរកមានស្ថាន |
| | ស្រវាចាប់អ្វីក៏ចាប់មិនបាន | ឃើញអ្វីៗ ក៏ជាការស្មាន |
| | ក្នុងស្ថានដែលមាន រស្មី។ | |
| ៣- | ដឹងហើយថាអូនជាស្រីអភ័ព្វ | រស់សម្រាប់ស្លាប់ |
| | ដោយចិត្ត ដែលឥតប្រណី | ស្ថានសួគ៌ងងឹត ស្ថានចិត្តអប្រិយ៍ |
| | ស្ថានស្នេហ៍ អវចី | សម្រាប់ស្រីដូចខ្ញុំ ៗ៕ |

## បោកព្រះ

*សំនៀងនារី*

*ពោល ៖ បោកប្រាស់មានន័យថាបំភាន់ឬបំភ្លាត់គេដោយសម្ដីឲ្យគេលង់គំនិតឬឲ្យគេបង់ទ្រព្យខូចប្រយោជន៍ ក្នុងន័យថាបោកគេរួចហើយក៏ប្រាសប្រាយបោលទៅ ។ ប្រើប្រាស់មានន័យថាប្រើទាំងសព្វ ទាំងគ្រប់ ប្រើតាមតែប្រទះ ។*

*ពាក្យ*បោកប្រាស់*ត្រូវបានលោកទស្សនវិទូខ្មែរម្នាក់សន្ទនាជាមួយខ្ញុំ ដោយបានបំភ្លាត់សម្លេងពាក្យថា*បោកព្រះ *ក្នុងន័យថាពួកទមិឡក្រៅសាសនា*បោកព្រះ*បានដោយច្រើនប្រការ ។*

*បើពាក្យ*បោកប្រាស់*អាចក្លាយទៅជា*បោកព្រះ*បាន ពាក្យ*ប្រើប្រាស់*ក៏អាចក្លាយទៅជាពាក្យ*ប្រើព្រះ*បាន ដូចតែគ្នា ។ កាលបើគេអាច*បោកព្រះ*បានហើយគេក៏អាច*ប្រើព្រះ*បានដែរ ។*

*បំរៀងបំពេបំប៉នចិត្តខ្មែរឲ្យថែអារម្មណ៍សន្សំនិស្ស័យប្រស្រ័យនឹងជាតិកុំឲ្យឃ្លាតឃ្លាពីគន្លងធម៌ឡើយ ម៉្លោះហើយនៅតែញ៉ែនឹងពាក្យបោកប្រាស់ឬ*បោកព្រះ *ប្រើប្រាស់ឬ*ប្រើព្រះ*គ្រប់ទិសទី ។*

១- *ព្រះបានត្រាស់ដឹងបុណ្ណឹងទៅហើយ　　មានអ្នកណាឡើយ*
*បោកប្រាស់ព្រះអង្គទៀតបាន　　អប្បអស់បញ្ញាខ្វាចផ្សាវិញ្ញាណ*
*ក្រុងមារឈ្នះពាន　　ទន្ទ្រានខ្មែរទៀតហើយ ។*

២- *មារអើយដឹងទេ* បោកព្រះ*ធ្វើអ្វី?　　បានជាអប្រិយ៍*
*បិដូច*ប្រើព្រះ*អង្គហើយ　　ព្រះល្អកន្លង ទ្រង់គង់ពុំធ្លើយ*
*ព្រះអង្គទ្រង់ព្រងើយ　　មិនធ្លើយប្រាប់មារបាន ។*

បន្ទរ- *ព្រះអង្គអឹមអៀមស្ងៀមក្នុងវិហារ　　ធម្មតា ឥតមានរំខានសន្ដាន*
*ខ្មែរណាគ្រប់ប្រាណគួរតែរាប់អាន　　គោរពព្រះ ទុកជាប្រធាន*
*ក្នុងស្ថានដែលមានរស្មី ។*

៣- *ដឹងហើយថាខ្មែរពូកែស្ទួតណាស់　　បោកប្រាស់ប្រើប្រាស់*
*ដោយចិត្ត ដែលឥតប្រណី　　ស្ថានសួគ៌ឯងនឹត ស្ថានចិត្តអប្រិយ៍*
*នរក អវចិ　　លង់បំភ័យអារម្មណ៍ ៗ*

# ចំប៉ាបាត់ដំបង

*សំនៀងគំរូ*

*លោកស៊ិនស៊ីសាមុត*

១- ឱ! បាត់ដំបងបណ្ដូលចិត្តអើយ    ខ្ញុំសូមលាហើយលាទាំងអាល័យ
តាំងពីរូបខ្ញុំឃ្លាតទៅឆ្ងាយ    ខ្វល់ខ្វាយនឹកស្ដាយពុំមានពេលល្ហែ។
២- ឱ! បាត់ដំបងកងកម្មវាសនា    ដែលខ្ញុំប្រាថ្នាគ្មានពេលទំនេរ
បើសិនជាគូខ្ញុំពីបុព្វេ    សូមឱ្យមាសស្នេហ៍នឹកឃើញគ្រាដើម។

បន្ទរ- កន្លងយូរឆ្នាំ ចាំទេអូន?    មានតែរូបអូនដែលជាដង្ហើម
ចំពោះនួនល្អងចិត្តបងសង្ឃឹម    ញញឹម ថាបាន ជាគូវាសនា។

៣- ឱ! បាត់ដំបងខ្ញុំប៉ងយូរហើយ    តើថ្ងៃណាឡើយបានយល់ភ័ក្ត្រា?
ចិត្តច្រួលច្របល់រាល់ថ្ងៃខ្លោចផ្សា    ចង់បានចំប៉ាបាត់ដំបងអើយ៕

# ឱ!បាដំបង

*សំនៀងបុរស*

*១- ឱ! បាដំបងធំក្រៃពេកហើយ    មេលែងឆ្ងល់ឆ្ងើយឆ្ងើយទាំងអាល័យ*
*តាំងតែពីមេឃ្លាតទៅឆ្ងាយ    ខ្វល់ខ្វាយនឹកស្ដាយពុំមានពេលល្ហែ ។*
*២- ឱ! បាដំបងកងកម្មវាសនា    ដែលមេប្រាថ្នាគ្មានពេលទំនេរ*
*បើសិនជាគូមេពីបុព្វេ    សូមឲ្យបាខ្មែរនឹកឃើញគ្រាដើម ។*

*បន្ទរ- កន្លងយូរឆ្នាំ ចាំទេបា?    មានតែរូបបាដែលជាដង្ហើម*
*ចំពោះរូបបាចិត្តមេសង្ឃឹម    ញញឹម ថាបាន ជាគូវាសនា ។*

*៣- ឱ! បាដំបងមេប៉ងយូរហើយ    តើថ្ងៃណាឡើយបានយល់ភ័ក្ត្របា?*
*ចិត្តច្រួលច្របល់រាល់ថ្ងៃខ្លោចផ្សា    ចង់បានតែបា បាដំបងអើយ ៕*